# មេរៀនទី២

## ចំណេះដឹងជាមូលដ្ឋាននៃអាហារូបត្ថម្ភ

ព័ត៌មានទូទៅអំពីអាហារូបត្ថម្ភ



## គោលបំណងមេរៀន

នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹងអាចៈ

1. កំណត់និយមន័យពាក្យគន្លឹះទាក់ទងនឹងមូលដ្ឋាននៃអាហារូបត្ថម្ភ
2. ប្រាប់ឈ្មោះក្រុមអាហារទាំងបីក្រុមដោយរៀបរាប់ពីតួនាទីរបស់ក្រុមអាហារនីមួយៗ
   នៅក្នុងរាងកាយ និងផ្តល់ឧទាហរណ៍ដែលមាននៅក្នុងអាហារក្រុមនីមួយៗ
3. អាចរៀបរាប់បានថា "តើថាមពលជាអ្វី" និងរៀបរាប់ពីតម្រូវការថាមពលសម្រាប់ក្រុមមនុស្សផ្សេងគ្នា
4. យល់អំពីការផ្លាស់ប្តូរនៃតម្រូវការអាហារូបត្ថម្ភក្នុងវដ្តជីវិតរបស់មនុស្ស

## *រយៈពេលៈ ៣ម៉ោងកន្លះ*

## *សម្ភារៈជំនួយបង្រៀន*

- "កញ្ចប់សម្ភារៈអាហារល្អ"
- ផ្ទាំងរូបភាពអំពីអាហារទាំងបីក្រុមរបស់អង្គការ ហេឡែនខេលល័រអន្តរជាតិ/កម្មវិធីជាតិអាហារូបត្ថម្ភ
- ក្រដាសផ្ទាំងធំ ឬក្តារខៀនសម្រាប់សរសេរហ្វឺត
- ហ្វឺតសម្រាប់សរសេរ
- កូនបាល់
- រូបភាពបាយក្នុងចានយកចេញពីកញ្ចប់សម្ភារៈ
- រូបភាពដើមស្រូវដែលលូតលាស់ល្អ (ខ្ពស់) និងលូតលាស់មិនល្អ (ទាប)
- បង់ស្អិត ឬម្ជុល

## *វិធីសាស្ត្របង្រៀន*

- ការធ្វើបទបង្ហាញដោយមានការចូលរួម
- ការបំផុសគំនិត
- ពិភាក្សាក្រុម
- ល្បែង

## សេចក្ដីផ្ដើម

រាងកាយមនុស្សយើងផ្សំឡើងដោយសារអាហារ និងទឹកដែលយើងបរិភោគ។ អាហារ និងទឹកមានផ្ទុកសារជាតិចិញ្ចឹមផ្សេងៗហើយសារធាតុចិញ្ចឹមនីមួយៗផ្ដល់អត្ថប្រយោជន៍ខុសៗគ្នាដល់រាងកាយយើង។ សារជាតិចិញ្ចឹមខ្លះផ្ដល់ឱ្យរាងកាយយើងនូវថាមពលខ្លះការពារយើងពីជំងឺ ហើយខ្លះទៀតជួយឱ្យសាច់ដុំ និងឆ្អឹងរបស់យើងលូតលាស់បានល្អ ដែលធ្វើឱ្យយើងមានសុខភាពមាំមួន។រាងកាយរបស់យើងត្រូវការរាល់សារជាតិចិញ្ចឹមទាំងនេះដើម្បីដំណើរការមុខងារសរីរាង្គឱ្យបានល្អ និងធ្វើឱ្យយើងមានសុខភាពល្អ និងរក្សាទម្ងន់បានល្អធម្មតា។ អាហារូបត្ថម្ភល្អបានមកពីការបរិភោគអាហារផ្សេងៗច្រើនមុខដែលចេញពីក្រុមអាហារផ្សេងគ្នាតាមបរិមាណមួយដែលត្រឹមត្រូវហើយវាផ្ដល់សារជាតិចិញ្ចឹមទាំងនោះតាមតម្រូវការរបស់រាងកាយដើម្បីបានសុខភាពល្អ។ ការបរិភោគអាហារក្នុងបរិមាណច្រើនតែមួយមុខនឹងបណ្ដាលឱ្យមានអតុល្យភាពក្នុងរាងកាយ និងនាំឱ្យរាងកាយមានជំងឺផ្សេងៗ។ ទារកអាចទទួលបានសារធាតុចិញ្ចឹមសម្រាប់លូតលាស់បានតែតាមរយៈការបំបៅដោះម្ដាយ ឬតាមការបៅទឹកដោះគោម្សៅតែប៉ុណ្ណោះ (អាហារជំនួស) ក្នុងរយៈពេល៦ខែ។ បន្ទាប់ពីដំណាក់កាលនេះ ស្ត្រីជាមាតាអាចឱ្យទារកបរិភោគអាហារជាលើកដំបូងបាន។ ក្នុងមេរៀននេះយើងនឹងសិក្សាអំពីគោលការណ៍ជាមូលដ្ឋាននៃអាហារូបត្ថម្ភខ្លះៗ សម្រាប់មនុស្សពេញវ័យ និងកុមារ។ នៅផ្នែកក្រោយៗនៃវគ្គបណ្ដុះបណ្ដាលនេះ យើងនឹងសិក្សាអំពីបញ្ហាអាហារូបត្ថម្ភជាក់លាក់សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា។

## បង្ហាញពីគោលបំណងមេរៀន

អ្នកសម្របសម្រួលបង្ហាញពីគោលបំណងនៃការសិក្សា (ដែលបានសរសេរដាក់លើក្រដាសផ្ទាំងធំ) ហើយសុំឱ្យសិក្ខាកាមម្នាក់អានឮៗដល់ក្រុម។ ពិភាក្សាអំពីគោលបំណងនីមួយៗជាមួយសិក្ខាកាម ដើម្បីឱ្យប្រាកដថាពួកគេបានយល់ពីខ្លឹមសាររបស់គោលបំណងមេរៀនបានច្បាស់លាស់។

> ❓ សួរសំណួរ
>
> មុននឹងបង្ហាញគោលបំណងមេរៀន សួរអ្នកចូលរួមៈ តើមាននរណាមានសំណួរឬទេ?

នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមទាំងអស់នឹងអាចៈ

1. កំណត់និយមន័យពាក្យគន្លឹះទាក់ទងនឹងមូលដ្ឋាននៃអាហារូបត្ថម្ភ
2. ប្រាប់ឈ្មោះក្រុមអាហារទាំងបីក្រុមដោយរៀបរាប់ពីតួនាទីរបស់ក្រុមអាហារនីមួយៗនៅក្នុងរាងកាយ និងផ្ដល់ឧទាហរណ៍ដែលមាននៅក្នុងអាហារក្រុមនីមួយៗ
3. អាចរៀបរាប់បានថា "តើថាមពលជាអ្វី" និងរៀបរាប់ពីតម្រូវការថាមពលសម្រាប់ក្រុមមនុស្សផ្សេងគ្នា
4. យល់អំពីការផ្លាស់ប្ដូរនៃតម្រូវការអាហារូបត្ថម្ភក្នុងវដ្ដជីវិតរបស់មនុស្ស។

## គោលបំណងទី១

សិក្ខាកាមនឹងអាចកំណត់និយមន័យពាក្យគន្លឹះទាក់ទងនឹងមូលដ្ឋាននៃអាហារូបត្ថម្ភ

វិធីសាស្ត្របង្រៀន៖ វិធីសាស្ត្របង្រៀនតាមបែបចូលរួម

ចាប់ផ្តើមការធ្វើបទបង្ហាញដោយសួរសំណួរទៅសិក្ខាកាមថា តើ "អាហារ" និង "អាហារូបត្ថម្ភ" មានអត្ថន័យខុសគ្នាយ៉ាងដូចម្តេច?

សរសេររាល់ចម្លើយដែលសិក្ខាកាមឆ្លើយនៅលើក្តារខៀន។

- អាហារ៖ ជាអ្វីដែលយើងអាចបរិភោគ និងផឹកបានហើយវាផ្តល់ថាមពល និងសារជាតិចិញ្ចឹមដល់រាងកាយដើម្បីជួយឱ្យរាងកាយអាចបំពេញមុខងារផ្សេងៗ។
- អាហារូបត្ថម្ភ៖ ជាដំណើរការនៃការស្រូបយក និងការរំលាយអាហាររបស់រាងកាយសម្រាប់ការលូតលាស់ការបន្តពូជ និងការរក្សាសុខភាព។

*សំណួរ៖* តើពាក្យ"សារជាតិចិញ្ចឹម" "មីក្រូសារជាតិ" និង"ម៉ាក្រូសារជាតិ" មានអត្ថន័យខុសគ្នាដូចម្តេច?

- សារជាតិចិញ្ចឹម៖ ជាសារធាតុដែលមានក្នុងអាហារដែលអាចត្រូវបានទទួលមេតាបូលិក ដើម្បីផ្តល់ថាមពលសម្រាប់ការរក្សាជួសជុល និងផលិតជាលិកានៃរាងកាយ។
- សារជាតិចិញ្ចឹមចែកចេញជា៖
    - » ម៉ាក្រូសារជាតិ៖ ជាតិស្ករ ប្រូតេអ៊ីន និងជាតិខ្លាញ់ (ត្រូវការក្នុងបរិមាណច្រើន)
    - » មីក្រូសារជាតិ៖ ជីវជាតិផ្សេងៗ និងជាតិខនិជ (ត្រូវការក្នុងបរិមាណតិចតួច)

## គោលបំណងទី២

សិក្ខាកាមនឹងអាចប្រាប់ឈ្មោះក្រុមអាហារទាំងបីក្រុម ដោយរៀបរាប់ពីតួនាទីរបស់ក្រុមអាហារនីមួយៗ

វិធីសាស្ត្របង្រៀន៖ការធ្វើបទបង្ហាញការពិភាក្សាក្រុមល្បែង

### ជំហានទី១៖ ការធ្វើបទបង្ហាញ និងការពិភាក្សាក្រុម

បិទផ្ទាំងរូបភាពរបស់អង្គការហេឡែនខេលល័រអន្តរជាតិ/កម្មវិធីជាតិអាហារូបត្ថម្ភស្តីពីអាហារទាំងបីក្រុម នៅកន្លែងណាដែលសិក្ខាកាមអាចមើលឃើញបានច្បាស់។

*សំណួរ៖* "តើអ្នកស្គាល់អាហារទាំងបីក្រុមនេះដែរទេ?"

សុំឱ្យសិក្ខាកាមរៀបរាប់ពីអាហារទាំងបីក្រុមរួចចង្អុលនៅលើផ្ទាំងរូបភាព។

*ពន្យល់ថា៖* ប្រភេទអាហារនិមួយៗមានប្រយោជន៍ផ្សេងៗគ្នាដល់រាងកាយរបស់យើង។ អាហារទាំងបីក្រុមនេះរួមមាន៖

1. *អាហារថាមពល៖* គឺអាហារពពួកជាតិម្សៅ ផ្អែមដូចជា បាយ គុយទាវ មី នំប៉័ង ដំឡូង ប្រេងឆា ។ល។ ជាធម្មតាអាហារថាមពលបានមកពីរុក្ខជាតិដែលមានពណ៌ស ឬពណ៌ត្នោត។ អាហារក្រុមនេះជាប្រភពដ៏សំខាន់នៃកាបូអ៊ីដ្រាត និងជាតិខ្លាញ់ ដែលផ្តល់ថាមពលសម្រាប់រាងកាយ។
2. *អាហារស្ថាបនារាងកាយ៖* សំដៅលើអាហារពពួកជាតិសាច់ ស៊ុត ដូចជាសាច់ ត្រី អន្ទង់ ស៊ុត កង្កែប ថ្លើម មាន់ ផលិតផលធ្វើពីទឹកដោះគោ ទឹកសណ្តែក សណ្តែកបាយ សណ្តែកសៀង និងតៅហ៊ូ។ល។ អាហារស្ថាបនារាងកាយនេះជាធម្មតាបានមកពីសាច់សត្វ ប៉ុន្តែគ្រាប់ផ្លែឈើ និងសណ្តែក (ដូចជា សណ្តែកសៀង ឬសណ្តែកបាយ) ក៏ជាអាហារស្ថាបនារាងកាយដែរ។ អាហារស្ថាបនារាងកាយមានផ្ទុកប្រូតេអ៊ីនដែលចាំបាច់សម្រាប់ការលូតលាស់ និងភាពមាំមួន និងធ្វើឱ្យសាច់ដុំរឹងមាំ និងមានមុខងារល្អប្រសើរ។
3. *អាហារការពាររាងកាយ៖* មានពពួកបន្លែ ឬផ្លែឈើពណ៌លឿងទុំ ឬពណ៌បៃតងចាស់មានដូចជា ត្រកួន ស្ពៃ ស្លឹកបាស ស្លឹកងប់ ល្ពៅ ការ៉ុត ល្ហុងទុំ ស្វាយទុំ ។ល។ អាហារការពាររាងកាយផ្ទុកនូវជីវជាតិសំខាន់ៗជាច្រើន និងជាតិខនិជ ដែលដំណើរការជាមួយអាហារស្ថាបនារាងកាយ និងអាហារថាមពលដើម្បីជួយរាងកាយរបស់យើងប្រឆាំងនឹងការឆ្លងរោគផ្សេងៗរក្សាទម្ងន់ឱ្យមានលំនឹងល្អ និងការពារជំងឺ និងមេរោគផ្សេងៗ។

*ពន្យល់៖* ដើម្បីទទួលបានសារជាតិចិញ្ចឹមដែលរាងកាយត្រូវការ យើងត្រូវបរិភោគអាហារប្រភេទផ្សេងៗគ្នា។ អាហារមួយប្រភេទពុំមានផ្ទុកសារជាតិចិញ្ចឹមគ្រប់គ្រាន់ទេ។ អាហារល្អគួរតែជាបន្សំនៃអាហារទាំងបីក្រុម នៅក្នុងបរិមាណគ្រប់គ្រាន់។ មនុស្សផ្សេងគ្នា ត្រូវការបរិមាណអាហារខុសគ្នា (ឧ. ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងអ្នករស់នៅជាមួយមេរោគអេដស៍ ត្រូវការអាហារច្រើនជាងធម្មតា) និងត្រូវការល្បាយអាហារផ្សេងគ្នា (ក្មេងៗ ឬអ្នកជំងឺត្រូវការអាហារទន់ៗ ឬកិនឱ្យម៉ត់)។ ការរៀបចំ ឬរបៀបចម្អិនអាហារក៏មានឥទ្ធិពលទៅលើកម្រិតជីវជាតិដែរ ដូចជាស្ងោរ ចំហុយ បក ឬមិនបកសំបក ឆ្អិន ឬឆៅ ជាដើម។

| |
|---|
| *សរសេរអាហារថាមពល ផ្នែកខាងលើ* |
| *សរសេរអាហារស្ថាបនា ផ្នែកកណ្តាល* |
| *សរសេរអាហារការពារ ផ្នែកខាងក្រោម* |

បិទក្រដាសផ្ទាំងធំលើជញ្ជាំង ឬនៅក្បែរផ្ទាំងរូបភាពនៃកម្មវិធីជាតិអាហារូបត្ថម្ភ រួចយកហ្វឺតគូសក្រដាសបែងចែកជាបីផ្នែក។

*សំណួរ៖* តើអ្នកអាចប្រាប់ឈ្មោះអាហារថាមពល អាហារសាងសង់ និងអាហារការពារខ្លះៗដែលប្រជាជនក្នុងតំបន់របស់អ្នកចូលចិត្តបរិភោគជាធម្មតាឬទេ?

ចូរសរសេរឈ្មោះអាហារដែលសិក្ខាកាមឆ្លើយ ទៅតាមផ្នែក នៅលើនៃក្រដាសផ្ទាំងធំ។ បន្ថែមអាហារសំខាន់ៗ ប្រសិនបើសិក្ខាកាមមិនបានរៀបរាប់។

*ពន្យល់៖* អាហារមួយចំនួនដែលមានបង្ហាញនៅក្នុងផ្ទាំងរូបភាពនេះអាចនឹងមានតម្លៃថ្លៃសម្រាប់អ្នកក្រទិញជារៀងរាល់ថ្ងៃ ប៉ុន្តែមានអាហារជាច្រើនប្រភេទផ្សេងទៀតដែលពួកគាត់អាចស្វែងរកបាននៅក្នុងសហគមន៍ ដើម្បីទទួលទានបានជាប្រចាំ។ យើងគួរស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីជួយពួកគេឱ្យមានលទ្ធភាពទទួលបានអាហារទាំងនេះ ដូចជាតាមរយៈ ការដាំស្ពនដំណាំតាមផ្ទះ ឬជួយពួកគាត់ក្នុងការបង្កើតសកម្មភាពរកប្រាក់ចំណូលផ្សេងៗ ជាដើម។

## ជំហានទី២៖ បទបង្ហាញ និងល្បែង

សុំឱ្យសិក្ខាកាមក្រឡេកមើលផ្ទាំងរូបភាពអំពីអាហារទាំងបីក្រុមរបស់កម្មវិធីជាតិអាហារូបត្ថម្ភ។

*សំណួរ៖* តើការបរិភោគ អាហារដែលមានគុណភាពល្អមានន័យដូចម្តេច?

*ពន្យល់ដល់សិក្ខាកាមថា៖* អាហារដែលមានគុណភាពល្អមានន័យថា យើងបរិភោគអាហារ និងភេសជ្ជៈពីអាហារក្រុមទាំងបី ឱ្យបានរាល់ថ្ងៃ។ ប្រសិនបើយើងបរិភោគតែអាហារមកពីក្រុមតែមួយ ដូចជា ក្រុមអាហារថាមពល នោះរាងកាយរបស់យើងនឹងមិនលូតលាស់ល្អ ឬមិនអាចការពារយើងពីការឆ្លងមេរោគបានឡើយ។ អាហារតាមក្រុមនីមួយៗផ្តល់នូវសារជាតិចិញ្ចឹមដែលមានសារៈសំខាន់ចំពោះរូបរាងកាយ។ ការទទួលទានបានល្អអាចជួយឱ្យអ្នករស់នៅជាមួយមេរោគអេដស៍មានសុខភាពល្អ និងឆ្លើយតបបានល្អទៅនឹងការប្រើប្រាស់ឱសថ។ វាមានសារៈសំខាន់ណាស់ក្នុងការបរិភោគទឹកឱ្យបានច្រើន ជាពិសេសទឹកដាំបានឆ្អិនល្អ (យ៉ាងតិចប្រាំបីកែវក្នុងមួយថ្ងៃ)។

*<u>ភេសជ្ជៈ និងសារធាតុរាវ</u>*

ទឹកមានសារៈសំខាន់ណាស់ចំពោះជីវិត និងក្នុងការរស់នៅប្រចាំថ្ងៃ។ មនុស្សម្នាក់ត្រូវការវត្ថុរាវប្រហែលពីរលីត្រក្នុងមួយថ្ងៃ។ រាងកាយរបស់មនុស្សត្រូវការទឹកកាន់តែច្រើននៅពេល៖

- ស្ថិតនៅក្នុងអាកាសធាតុក្តៅ
- កំពុងធ្វើការ ឬធ្វើសកម្មភាពរាងកាយ ច្រើនជាងមុន
- បែកញើស ឬកើតរាករូស ក្អួត និងក្តៅខ្លួន។

សារធាតុរាវ ជាពិសេសទឹក មានសារៈសំខាន់ក្នុងការបង្កើតទឹកដោះម្ដាយបានល្អ។ ស្ត្រីជាច្រើនស្រេកទឹក ក្នុងពេលបំបៅដោះកូន និងជាសញ្ញាមួយដែលបង្ហាញថា ពួកគាត់ត្រូវការបរិភោគទឹកឱ្យបានច្រើន។ ក្មេងៗក៏ត្រូវការទឹកគ្រប់គ្រាន់ដែរ ប៉ុន្តែមិនត្រូវឱ្យក្មេងៗទទួលទានធាតុរាវផ្សេងៗជំនួសអាហារនោះទេ។ សូមចងចាំថា ការបំបៅទឹកដោះកូនតែមួយមុខ (សម្រាប់ទារកក្រោមអាយុ៦ខែ) មិនត្រូវការទឹកបន្ថែមទេ។ ចូរប្រើទឹកពីអណ្តូងដែលគ្រប/ការពារបានល្អ ឬប្រភពទឹកសមស្រប ដោយត្រូវយកទឹកនោះទៅដាំឱ្យពុះបានរយៈពេលយ៉ាងហោច១០នាទី និងរក្សាទុកនៅកន្លែងស្អាត។

ក្រៅពីការបរិភោគទឹកស្អាតដែលមានសុវត្ថិភាព សូមបរិភោគសារធាតុរាវផ្សេងៗទៀត ដូចជា ទឹកតែ ទឹកផ្លែឈើស្រស់ ទឹកដូង ផលិតផលធ្វើពីទឹកដោះគោ ទឹកសណ្តែក ទឹកស៊ុប ។ល។

## ជំហានទី៣៖ ការពិភាក្សាក្រុម

*សំណួរ៖* តើអតិថិជនរបស់អ្នកបរិភោគអាហារមានតុល្យភាពល្អដែរទេ? តើក្រុមអាហារមួយណាដែលពួកគេបរិភោគច្រើនជាងគេ? តើក្រុមអាហារមួយណាពួកគេបរិភោគតិចជាងគេ? តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីលើកទឹកចិត្តឱ្យពួកគេបរិភោគអាហារទាំងបីក្រុម? តើភេសជ្ជៈអ្វីដែលពួកគេបរិភោគ?

## ជំហានទី៤៖ ល្បែង

*ប្រាប់សិក្ខាកាមថា៖* ឥឡូវនេះ យើងនឹងលេងល្បែងមួយដើម្បីជួយយើងឱ្យចងចាំពីអត្ថប្រយោជន៍នៃក្រុមអាហារទាំងបី។

សុំឱ្យសិក្ខាកាមក្រោកឈរឡើងជារង្វង់ ឱ្យពួកគេសម្រេចធ្វើចលនាមួយដើម្បីតំណាងឱ្យអាហារមួយក្រុម ដូច្នេះពួកគេត្រូវកំណត់ចលនាចំនួនបី។ ខាងក្រោមនេះគឺជាឧទាហរណ៍៖

- កាយវិការដើរ ឬរត់មួយកន្លែង តំណាងឱ្យក្រុមអាហារថាមពល។
- កាយវិការបញ្ចោញសាច់ដុំដៃ រលាស់ដៃ ឬដាក់ឱ្យដៃទាំងពីរឱ្យខ្ពស់ទៅលើក្បាល តំណាងឱ្យក្រុមស្ថាបនារាងកាយ។
- ចង្អុលក្បាល ឬទ្រូង ឬទាំងពីរ តំណាងឱ្យក្រុមអាហារការពាររាងកាយ។

សុំឱ្យសិក្ខាកាមទាំងអស់ហាត់ធ្វើចលនាដែលបានព្រមព្រៀងគ្នា។ អ្នកសម្របសម្រួលចាប់ផ្តើមលេងល្បែងនេះដោយចង្អុលទៅកាន់សិក្ខាកាមម្នាក់ រួចនិយាយឈ្មោះអាហារមួយ (ឧ. ដូង ចេក បង្គារ ខ្ទឹម) ។ល។ ពេលត្រូវបានចង្អុល សិក្ខាកាមឆ្លើយក្រុមអាហារ

ឱ្យបានត្រឹមត្រូវ បន្ទាប់មកធ្វើចលនាតំណាងឱ្យក្រុមអាហារនេះ (ឧ. ដូង ស្ថិតក្នុងក្រុមអាហារថាមពល ដូច្នេះសិក្ខាកាមដើរ ឬរត់នៅមួយកន្លែង។ ចេក ស្ថិតនៅក្នុងក្រុមអាហារការពារ ដូច្នេះសិក្ខាកាមចង្អុលក្បាល ឬដើមទ្រូងរបស់គាត់ ។ល។) សិក្ខាកាមម្នាក់ៗបន្តធ្វើចលនារបស់ខ្លួនរហូត ទាល់តែអ្នកសម្របសម្រួលចង្អុលទៅកាន់ពួកគេម្តងទៀតជាមួយឈ្មោះអាហារផ្សេង ឬរហូតដល់ល្បែងនេះចប់។

> **កំណត់សម្គាល់**
>
> ខាងក្រោមនេះជាល្បែងដែលទាក់ទងនឹងអាហារដែលអាចជួយសិក្ខាកាមក្នុងការបែងចែកក្រុមអាហារបានច្បាស់លាស់ពីក្រុមអាហារ និងអាហារចម្រុះដែលគេច្រើនចម្អិននៅផ្ទះ។

### *សង្ខេបខ្លឹមសារៈ*

សុំឱ្យសិក្ខាកាមរំលឹកឡើងវិញនូវអាហារទាំងបីក្រុម និងគោលបំណងនៃការបរិភោគអាហារទាំងបីក្រុមនេះ។

## ល្បែងសំដែងអំពីប្រភេទអាហារ

- ផ្តល់ក្រដាសតូចៗ យ៉ាងតិចពីរសន្លឹក ដល់សិក្ខាកាមម្នាក់ៗ និងសុំឱ្យពួកគេគូរ ឬសរសេរឈ្មោះគ្រឿងផ្សំនៅលើក្រដាស។ គ្រឿងផ្សំអាចជាអាហារណាមួយ ដូចជាសាច់សត្វ បន្លែ ឬផ្លែឈើណាមួយ ។ល។ ដោយក្រដាសមួយសន្លឹកសម្រាប់សរសេរមួយមុខ និងមិនអាចសរសេរមុខម្ហូបដែលលាយគ្រឿងហើយស្រេចនោះទេ (ឧ. មិនអាចសរសេរ សម្លត្រីបានទេ)។
- ប្រមូលក្រដាសទាំងអស់ ហើយដាក់លាយចូលគ្នានៅក្នុងកន្ត្រកមួយ។ សរសេរឈ្មោះក្រុមអាហារទាំងបី នៅលើក្រដាសផ្ទាំងធំៗចំនួនបីផ្ទាំង ដាក់លាតត្រដាងនៅលើកំរាលកណ្តាលបន្ទប់។
- សុំឱ្យសិក្ខាកាមម្នាក់ៗយកក្រដាស២សន្លឹកចេញពីកន្ត្រក ហើយបិតលើក្រដាសផ្ទាំងធំ ទៅតាមក្រុមអាហារ។ សួរក្រុមធំថា តើមានការបែងចែកត្រឹមត្រូវ ឬទេ។

## ល្បែងអាហារចម្រុះ

នៅពេលបែងចែកប្រភេទអាហារខាងលើរួច គូររូបចានបីដោយដាក់ឈ្មោះថា អាហារពេលព្រឹក អាហារពេលថ្ងៃត្រង់ និងអាហារពេលល្ងាច។ សុំសិក្ខាកាមស្ម័គ្រចិត្តបីនាក់ឡើងមកបង្កើតអាហារដោយប្រើគ្រឿងផ្សំនៅលើក្រដាសផ្ទាំងធំ។ អ្នកស្ម័គ្រចិត្តម្នាក់ៗរើសយកក្រដាសគ្រឿងផ្សំ និងបង្កើតជាអាហារពេលព្រឹក ថ្ងៃត្រង់ និងល្ងាច។ ព្យាយាមរៀបចំឱ្យមានប្រភេទអាហារ/គ្រឿងផ្សំច្រើនមុខ។

ដឹកនាំការពិភាក្សាជាមួយសិក្ខាកាម ដោយប្រើសំណួរខាងក្រោមៈ

- តើអាហារនេះជាអាហារសុខភាព ចម្រុះ និងមានតុល្យភាពទេ?
- តើភេសជ្ជៈអ្វីខ្លះដែលអាចទទួលទានបានជាមួយអាហារពេលនីមួយៗ?
- ធ្វើដូចម្តេចដើម្បីលើកទឹកចិត្តអ្នករស់នៅជាមួយមេរោគអេដស៍ឱ្យបរិភោគអាហារដែលមានបន្លែ និងផ្លែឈើចម្រុះ?

## គោលបំណងទី៣៖

សិក្ខាកាមនឹងអាចរៀបរាប់ថាអាចរៀបរាប់បានថា "តើថាមពលជាអ្វី" និងរៀបរាប់ពីតម្រូវការថាមពលសម្រាប់ក្រុមមនុស្សផ្សេងគ្នា

វិធីសាស្ត្របង្រៀន៖បទបង្ហាញ និងការប្រលងតេស្ត

## ជំហានទី១៖ បទបង្ហាញ

*ប្រាប់សិក្ខាកាមថា៖* យើងនឹងមានបទបង្ហាញខ្លីមួយ ហើយបន្ទាប់មកលេងល្បែងសំណួរមួយ ដូច្នេះសូមព្យាយាមចងចាំអ្វីដែលអ្នកនឹងឃើញ និងបានស្តាប់ឮ។

យើងបរិភោគអាហារដើម្បីបំពេញថាមពល បន្តលូតលាស់ និងជួលជុល/ថែទាំរាងកាយ។ "កាឡូរី" គឺជាឯកតារង្វាស់ថាមពលដែលយើងទទួលបានពីអាហារដែលយើងបរិភោគ។ ទាំងនេះគឺជាឧទាហរណ៍ខ្លះៗ នៃឯកតារង្វាស់ដែលយើងប្រើជាប្រចាំសម្រាប់ពេលវេលា ចម្ងាយ និងទម្ងន់។

### *ឧទាហរណ៍នៃឯកតារង្វាស់*

» នាទី និងម៉ោង- រង្វាស់ពេលវេលា

» អង្សាសេ(°C)- រង្វាស់សីតុណ្ហភាព

» ម៉ែត្រ(ម)- រង្វាស់ចម្ងាយ

» ក្រាម(ក្រ)- រង្វាស់ទម្ងន់

» កាឡូរី(កឡរ)- រង្វាស់ថាមពលដែលបានមកពីអាហារដែលយើងបរិភោគ

*ពន្យល់៖* រាល់អាហារ និងភេសជ្ជៈទាំងអស់មានផ្ទុកទៅដោយកាឡូរី (ថាមពល)។ ក្នុងកញ្ចប់សម្ភារៈនេះនៅពេលដែលយើងនិយាយពីកាឡូរីដែលមានក្នុងអាហារ គឺយើងសំដៅលើ"ថាមពល"។ បាយ សម្ល ប្រេងឆា ស្ករ សាច់ ត្រី បន្លែ ផ្លែឈើជាដើមសុទ្ធតែផ្តល់កាឡូរី។ អាហារ និងភេសជ្ជៈទាំងអស់អាចផ្តល់ថាមពល តិច ឬច្រើន។ អាហារដូចជា ប្រេងឆា សាច់ និង ផ្លែឈើមួយចំនួនដូចជាចេក ក្នុង១ក្រាមមានថាមពលច្រើនជាងបាយធម្មតា។ បន្លែបៃតងមានបរិមាណថាមពលទាប ប៉ុន្តែនេះមិនមានន័យថាវាគ្មានសារៈសំខាន់នោះទេ។ បន្លែទាំងនេះមានសារៈសំខាន់ណាស់ ព្រោះពួកវាមានជីវជាតិច្រើនមុខដែលជួយថែទាំយើងឱ្យមានសុខភាពល្អ។

ភេសជ្ជៈភាគច្រើនមានកាឡូរី ឧទាហរណ៍ ទឹកផ្លែឈើ ទឹកដោះគោ ទឹកសណ្តែក និង ភេសជ្ជៈដែលមានជាតិស្ករ។ ទឹកធម្មតា និងទឹកតែដែលគ្មានជាតិស្ករ គ្មានកាឡូរីទេ។ ប៉ុន្តែមិនមែនមានន័យថាទឹកធម្មតាមិនសំខាន់នោះទេ។ ទឹកមានសារៈសំខាន់ណាស់ ព្រោះរាងកាយត្រូវការជាតិទឹកជានិច្ចដើម្បីសម្រួលដំណើរមុខងារសរីរាង្គ និងទប់ទល់នឹងជំងឺ។

*បង្ហាញចានបាយនៅក្នុងកញ្ចប់សម្ភារៈហើយសួរសំណួរ៖*

តើចានបាយមួយណាផ្តល់កាឡូរីច្រើនជាងគេ?

*ពន្យល់៖* បាយក្នុងបរិមាណខុសគ្នាមានបរិមាណកាឡូរីខុសគ្នាដែរ។ បើអ្នកកាន់តែបរិភោគច្រើន អ្នកកាន់តែទទួលកាឡូរីច្រើនដែរ។ មនុស្សមានតម្រូវការផ្សេងគ្នាដូច្នេះ ត្រូវការបរិភោគបរិមាណអាហារផ្សេងគ្នាដែរ អាស្រ័យលើអាយុ ភេទ និងសកម្មភាព ឬមានផ្ទៃពោះ បំបៅដោះកូន ឬមានជំងឺ ឬអត់។ មនុស្សធាត់ ឬលើសទម្ងន់ ពេលខ្លះត្រូវព្យាយាមកំណត់កាឡូរីត្រូវទទួលទាន (តមអាហារ)។ មនុស្សស្គម ឬមនុស្សមានជំងឺត្រូវការបន្ថែមកាឡូរី ដើម្បីឡើងទម្ងន់ ឬកុំឱ្យស្គមពេក។ មានន័យថាពួកគេត្រូវការបរិភោគអាហារបន្ថែមជាទូទៅ ឬត្រូវបន្ថែមអាហារជាក់លាក់ណាមួយដែលមានកាឡូរីខ្ពស់ទៅក្នុងរបបអាហារដែលមានស្រាប់។

សុំឱ្យសិក្ខាកាម មើលតារាងដែលបង្ហាញពីតម្រូវការកាឡូរីប្រចាំថ្ងៃសម្រាប់មនុស្សរួមទាំងអ្នករស់នៅជាមួយមេរោគអេដស៍ក្នុងឯកសារមេរៀនទី២ (ក្នុងសៀវភៅសម្រាប់អ្នកចូលរួម)។

> **កំណត់សម្គាល់**
>
> អ្នកមិនចាំបាច់ចងចាំចំនួនពិតប្រាកដនៃតម្រូវការថាមពលសម្រាប់ក្រុមនីមួយៗទេ ប៉ុន្តែសំខាន់អ្នកត្រូវដឹងថា អ្នកណាត្រូវការថាមពលបន្ថែម និងហេតុអ្វី។

សរសេរ និងពន្យល់ដល់សិក្ខាកាម អំពីព័ត៌មានខាងក្រោមលើក្រដាសផ្ទាំងធំ។ យើងចាប់ផ្តើមជាមួយមនុស្សពេញវ័យ (បុរស និងស្ត្រី)៖

- បុរសត្រូវការប្រហែល ២៥០០ កាឡូរីក្នុងមួយថ្ងៃ
- ស្ត្រីត្រូវការប្រហែល ២០០០ កាឡូរីក្នុងមួយថ្ងៃ

*សំនួរ៖* ហេតុអ្វីបានជាស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូនត្រូវការថាមពលបន្ថែម?

បន្ទាប់ពីសិក្ខាកាមមានឱកាសឆ្លើយសំណួររួច ពន្យល់ថា៖ រាងកាយរបស់ស្ត្រីមានផ្ទៃពោះត្រូវការថាមពលបន្ថែមដើម្បីទ្រទ្រង់ទារកក្នុងផ្ទៃ និងនៅពេលគាត់បំបៅដោះកូន។ ដូច្នេះ ពួកគាត់ត្រូវការថាមពលច្រើនទៀតដើម្បីទ្រទ្រង់កិច្ចការបន្ថែមទាំងនេះ។

ក្មេងភាគច្រើន លើកលែងក្មេងអាយុ១៥–១៨ឆ្នាំ មានតម្រូវការថាមពលតិចជាងមនុស្សពេញវ័យ។ ប៉ុន្តែ បើនិយាយពីតម្រូវការថាមពលក្នុងទម្ងន់ខ្លួនមួយគីឡូក្រាមវិញ

| ក្រុម | តម្រូវការថាមពល | កំណើនភាគរយ |
|---|---|---|
| មនុស្សប្រុស | ២៥០០ កាឡូរី/ថ្ងៃ | - |
| មនុស្សស្រី | ២០០០ កាឡូរី/ថ្ងៃ | - |
| ស្ត្រីមានផ្ទៃពោះ | ត្រូវការបន្ថែម ២០០ ទៅ ៥០០ កាឡូរី/ថ្ងៃ | ១០ (ត្រីមាសទី២)<br>២៥ (ត្រីមាសទី៣) |
| ស្ត្រីបំបៅកូនដោយទឹកដោះ | ត្រូវបន្ថែម ៥០០ កាឡូរី/ថ្ងៃ | ២៥ |
| ក្មេង និងវ័យជំទង់(អាយុ ០–១៩ឆ្នាំ) | ពី៥២០ ទៅ ២៧៥៥ កាឡូរី/ថ្ងៃ | |
| **អ្នករស់នៅជាមួយមេរោគអេដស៍** | | |
| បុរសដែលរស់នៅជាមួយមេរោគអេដស៍ | ត្រូវការបន្ថែម ២៥០កាឡូរី/ថ្ងៃ | ១០ |
| ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ | ត្រូវការបន្ថែម ២០០កាឡូរី/ថ្ងៃ | ១០ |
| ក្មេងដែលរស់នៅជាមួយមេរោគអេដស៍ | ផ្សេងៗ ត្រូវការបន្ថែម ១០% | ១០ |
| ស្ត្រីមានផ្ទៃពោះដែលរស់នៅជាមួយមេរោគអេដស៍ | ត្រូវការបន្ថែម ៧០០កាឡូរី/ថ្ងៃ | ៣៥ |
| ស្ត្រីបំបៅកូនដោយទឹកដោះដែលរស់នៅជាមួយមេរោគអេដស៍ | ត្រូវការបន្ថែម ៧០០កាឡូរី/ថ្ងៃ | ៣៥ |
| **អ្នករស់នៅជាមួយមេរោគអេដស៍ដែលឈឺ** | | |
| ក្មេងដែលរស់នៅជាមួយមេរោគអេដស៍ ហើយមានទម្ងន់មិនគ្រប់ ឬមានរោគសញ្ញាផ្សេងៗ | បន្ថែមចាប់ពី ២០%ឡើង | ២០ |
| មនុស្សប្រុសដែលរស់នៅជាមួយមេរោគអេដស៍ហើយមានជំងឺ | ត្រូវការបន្ថែម ៥០០ទៅ ៧៥០កាឡូរី/ថ្ងៃ | ២០ ទៅ៣០ |
| ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ ហើយមានជំងឺ | ត្រូវការបន្ថែម ៤០០ទៅ ៦០០ កាឡូរី/ថ្ងៃ | ២០ ទៅ៣០ |
| ក្មេងដែលរស់នៅជាមួយមេរោគអេដស៍ ហើយមានជំងឺ (កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ) | ៥០ ទៅ១០០% | ៥០ ទៅ១០០ |

ប្រភព៖ FAO 2002, WHO 2004, WHO 2005

ក្មេងត្រូវការថាមពលច្រើនជាង។ មានន័យថា បើធៀបនឹងទម្ងន់ ក្មេងមានតម្រូវការបរិភោគច្រើនជាងមនុស្សពេញវ័យ ជាពិសេសក្នុងរយៈពេលបីខែដំបូងបន្ទាប់ពីកើត។

ពន្យល់ និងបង្ហាញនូវសំណេរលើក្រដាសផ្ទាំងធំដូចខាងក្រោម៖

- បុរសដែលរស់នៅជាមួយមេរោគអេដស៍ (តែគ្មានជំងឺ) ត្រូវការថាមពល ១០% ថែមទៀត។ សរុបប្រហែល ២៧៥០កាឡូរី/ថ្ងៃ។
- ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ (តែគ្មានជំងឺ) ត្រូវការថាមពល ១០% ថែមទៀត។ សរុបប្រហែល ២២០០ កាឡូរី/ថ្ងៃ។
- កុមារដែលរស់នៅជាមួយមេរោគអេដស៍ (តែគ្មានជំងឺ) ក៏ត្រូវការថាមពល ១០% ថែមទៀតដែរ។ សរុប ៥២០ ទៅ ២៧៥៥កាឡូរី/ថ្ងៃ អាស្រ័យលើអាយុកុមារ។

*សំនួរ៖* អ្នកគិតថា ហេតុអ្វីបានជាអ្នករស់នៅជាមួយមេរោគអេដស៍ត្រូវការប្រើប្រាស់ថាមពលបន្ថែម?

*ពន្យល់៖* នៅពេលមនុស្សម្នាក់បានឆ្លងមេរោគដូចជាមេរោគអេដស៍ រាងកាយរបស់គេត្រូវការប្រើប្រាស់ថាមពលច្រើន និងសារជាតិចិញ្ចឹមពីអាហារ ដើម្បីការពាររាងកាយប្រឆាំងមេរោគ និងថែទាំរាងកាយឱ្យមានសុខភាពល្អ។ ហេតុដូច្នេះ នៅពេលមានជំងឺពួកគេត្រូវការថាមពលកាន់តែច្រើន។

អ្នករស់នៅជាមួយមេរោគអេដស៍ត្រូវថាមពលបន្ថែម។ សូមលើកទឹកចិត្តឱ្យពួកគេ៖

- បង្កើនភាពញឹកញាប់ក្នុងការបរិភោគអាហារពេល និងអាហារសម្រន់៖ គេអាចបន្ថែមថាមពលតាមរយៈ ការបរិភោគអាហារបន្ថែមជាប្រចាំ ឬបរិភោគឱ្យបានញឹកញាប់ជាងមុន ដូចជាអាហារតិចៗ នៅចន្លោះបីទៅបួនម៉ោងម្តង។
- បង្កើនបរិមាណនៃអាហារ៖ គេអាចបង្កើនថាមពលតាមរយៈការបរិភោគអាហារបន្ថែម ឧ. បន្ថែមអាហារមួយ ឬពីរក្តាប់ដៃ។
- បង្កើនភាពចម្រុះនៃអាហារផ្សេងៗ ដែលសំបូរទៅដោយសារជាតិចិញ្ចឹម និងស្ថិតនៅក្នុងក្រុមអាហារទាំងបី។

ចាំបាច់ត្រូវពន្យល់ប្រាប់សិក្ខាកាមថា ពេលបន្ថែមថាមពល មិនគួរបន្ថែមតែអាហារក្នុងក្រុមណាមួយតែមួយមុខនោះទេ គឺត្រូវបន្ថែមឱ្យបានសមាមាត្រគ្នានៅក្នុងគ្រប់ក្រុមអាហារទាំងអស់។

ពន្យល់ និងបង្ហាញនូវអ្វីដែលអ្នកសរសេរលើក្រដាសផ្ទាំងធំ៖

- បុរសដែលរស់នៅជាមួយមេរោគអេដស៍ (និងឈឺដោយសារជំងឺឆ្លង) ត្រូវការថាមពលបន្ថែម ២០–៣០% ។ សរុបប្រហែល ៣១២៥កាឡូរី/ថ្ងៃ។
- ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ (និងឈឺដោយសារជំងឺឆ្លង តែមិនស្រកទម្ងន់) ត្រូវការថាមពលបន្ថែម២០–៣០%។ សរុបប្រហែល ២៥០០កាឡូរី/ថ្ងៃ។

- ក្មេងដែលរស់នៅជាមួយមេរោគអេដស៍ (និងឈឺដោយសារជំងឺឆ្លង) ត្រូវការថាមពលបន្ថែម ២០–៣០%។
- ក្មេងដែលរស់នៅជាមួយមេរោគអេដស៍ (និងឈឺដោយសារជំងឺឆ្លង និងស្រកទម្ងន់) ត្រូវការថាមពលបន្ថែម ៥០–១០០%។

*សង្ខេបខ្លឹមសារ៖*

សួរសំណួរដល់សិក្ខាកាម ហើយទុកឱ្យពួកគេឆ្លើយ៖

1. តើនរណាត្រូវការថាមពលច្រើនជាងរវាងបុរស និងស្ត្រីមានផ្ទៃពោះ និង/ឬ ស្ត្រីបំបៅដោះកូន?
   *ចម្លើយ៖* ស្ត្រីមានផ្ទៃពោះ និង/ឬ ស្ត្រីបំបៅដោះកូន
2. តើនរណាត្រូវការថាមពលច្រើនជាងរវាង អ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នកគ្មានផ្ទុកមេរោគអេដស៍?
   *ចម្លើយ៖* អ្នករស់នៅជាមួយមេរោគអេដស៍
3. តើនរណាត្រូវការថាមពលច្រើនជាងរវាង អ្នករស់នៅជាមួយមេរោគអេដស៍ ដែលមានជំងឺ និងអ្នករស់នៅជាមួយមេរោគអេដស៍ដែលគ្មានជំងឺ?
   *ចម្លើយ៖* អ្នករស់នៅជាមួយមេរោគអេដស៍ដែលមានជំងឺ
4. តើនរណាត្រូវការថាមពលច្រើនជាងរវាង ក្មេងដែលមានជំងឺ និងក្មេងគ្មានជំងឺ?
   *ចម្លើយ៖* ក្មេងដែលមានជំងឺ

## ជំហានទី២៖ ល្បែងចោទសួរ

សុំឱ្យសិក្ខាកាមក្រោកឈរជារង្វង់។ អ្នកសម្របសម្រួលនឹងបោះកូនបាល់ទៅកាន់សិក្ខាកាមម្នាក់ ហើយសួរមួយសំណួរ។ ប្រសិនបើគាត់ឆ្លើយសំណួរនេះពុំត្រឹមត្រូវទេ គាត់នឹងត្រូវច្រៀងចម្រៀងមួយបទ ឬរាំ រួចគាត់ត្រូវបោះកូនបាល់បន្តទៅកាន់សិក្ខាកាមផ្សេងទៀត ដែលត្រូវព្យាយាមឆ្លើយសំណួរដដែល។ នៅពេលមានអ្នកឆ្លើយសំណួរនេះត្រូវ អ្នកសម្របសម្រួលនឹងសួរសំណួរថ្មី និងបោះបាល់ទៅកាន់សិក្ខាកាមបន្តទៀត។

បោះកូនបាល់កាត់រង្វង់ទៅកាន់អ្នកដែលនៅទល់មុខគ្នា កុំហុចឱ្យអ្នកនៅជាប់គ្នា។ កុំបោះបាល់ឱ្យអ្នកដែលបានឆ្លើយសំណួររួចហើយ។ ធ្វើយ៉ាងណាឱ្យសិក្ខាកាមមានឱកាសឆ្លើយសំណួរឱ្យបានគ្រប់គ្នា។

សំណួរសម្រាប់ល្បែងចោទសួរខាងលើនេះ៖

1. តើកាឡូរីជារង្វាស់សម្រាប់អ្វី?
   *ចម្លើយ៖* កាឡូរីជារង្វាស់សម្រាប់ថាមពលបានមកពីចំណីអាហារដែលយើងបរិភោគ។

2. តើចំណីអាហារទាំងអស់សុទ្ធតែមានថាមពល ឬតែមួយចំនួនទេ?
*ចម្លើយ៖* ចំណីអាហារទាំងអស់សុទ្ធតែមានថាមពល។
3. តើអ្នកណាត្រូវការថាមពលច្រើនជាងរវាង អ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នកគ្មានផ្ទុកមេរោគអេដស៍?
*ចម្លើយ៖* អ្នករស់នៅជាមួយមេរោគអេដស៍ត្រូវការថាមពលបន្ថែមច្រើនជាងអ្នកមិនផ្ទុកមេរោគអេដស៍។
4. តើអ្នកណាត្រូវការថាមពលច្រើនជាងរវាងអ្នករស់នៅជាមួយមេរោគអេដស៍ដែលមានជំងឺ និងអ្នករស់នៅជាមួយមេរោគអេដស៍ដែលគ្មានជំងឺ?
*ចម្លើយ៖* អ្នករស់នៅជាមួយមេរោគអេដស៍ដែលមានជំងឺត្រូវការថាមពលច្រើនជាង។
5. តើក្រុមអាហារទាំងបីមានអ្វីខ្លះ?
*ចម្លើយ៖* អាហារថាមពល អាហារស្ថាបនារាងកាយ និងអាហារការពាររាងកាយ។
6. តើសាច់សត្វស្ថិតក្នុងក្រុមមួយណា?
*ចម្លើយ៖* ក្រុមអាហារស្ថាបនារាងកាយ។
7. តើបាយ គុយទាវ និងស្ករ ស្ថិតក្នុងក្រុមមួយណា?
*ចម្លើយ៖* ក្រុមអាហារថាមពល។
8. តើបន្លែ និងផ្លែឈើស្ថិតក្នុងក្រុមមួយណា?
*ចម្លើយ៖* ក្រុមអាហារការពាររាងកាយ។
9. តើអាហារមានតុល្យភាពមានន័យដូចម្តេច?
*ចម្លើយ៖* គឺជាការបរិភោគចំណីអាហារ និងភេសជ្ជៈនៃក្រុមអាហារទាំងបីរៀងរាល់ថ្ងៃ។

អ្នកសម្របសម្រួលអាចបន្ថែមសំណួរខ្លួនឯង ដើម្បីរម្លឹកខ្លឹមសារក្នុងមេរៀននេះ។

នៅចុងបញ្ចប់នៃល្បែងចោទសួរនេះ អបអរសាទរដល់សិក្ខាកាមដែលបានឆ្លើយត្រឹមត្រូវ និងថ្លែងអំណរគុណដល់ពួកគេដែលបានចូលរួមច្រៀង/រាំកំសាន្តជាមួយក្រុម។

## គោលបំណងទី៤

សិក្ខាកាមអាចយល់អំពីការផ្លាស់ប្តូរនៃតម្រូវការអាហារូបត្ថម្ភក្នុងវដ្តជីវិតរបស់មនុស្ស

វិធីសាស្ត្របង្រៀន៖ ការធ្វើបទបង្ហាញ និងការបំផុសគំនិត

### ជំហានទី១៖ ការធ្វើបទបង្ហាញ និងការបំផុសគំនិត

*ពន្យល់៖* តម្រូវការអាហារូបត្ថម្ភមានភាពខុសគ្នាទៅតាមដំណាក់កាលក្នុងវដ្តជីវិត។ ថ្វីបើយើងត្រូវការជីវជាតិអាហារជាមូលដ្ឋានដូចគ្នាក៏ដោយ នៅក្នុងដំណាក់កាលជីវិត

នីមួយៗ មនុស្សមានតម្រូវការអាហារូបត្ថម្ភជាក់លាក់ផ្សេងៗគ្នា។ ជាធម្មតា កង្វះអាហារូបត្ថម្ភចាប់ផ្ដើមតាំងពីកើតឡើងនៅមុនកំណើត និងបន្តរហូតដល់វ័យជំទង់ និងពេញវ័យ ជាពិសេសសម្រាប់ក្មេងស្រី និងស្ត្រី។

កង្វះអាហារូបត្ថម្ភអាចបន្តពីមួយជំនាន់ទៅមួយជំនាន់ផ្សេងទៀត។ ក្មេងស្រីដែលមានការលូតលាស់ខ្សោយនឹងក្លាយជាស្ត្រីក្រិន និងអាចបង្កើតបាននូវទារកតូច ដែលអាចក្លាយទៅជា ក្មេងតូចល្អិត និងក្លាយទៅជាក្មេងជំទង់តូច រួចក្លាយទៅជាមនុស្សពេញវ័យតូច។ ស្ត្រីដែលមានផ្ទៃពោះនៅវ័យក្មេង អាចបង្កើនគ្រោះថ្នាក់ដោយសារកង្វះទម្ងន់ទារកនៅពេលកើត និងពិបាកក្នុងចាកចេញពីវដ្ដនៃកង្វះអាហារូបត្ថម្ភ។

យើងត្រូវការចាំបាច់នូវអាហារូបត្ថម្ភល្អ ដើម្បីទ្រទ្រង់នៅក្នុងគ្រប់ដំណាក់កាលនៃវដ្ដជីវិតមុនកំណើតទារកភាព កុមារភាព វ័យជំទង់ និងពេលពេញវ័យ។ នៅក្នុងមេរៀននេះ យើងនឹងរម្លឹកពីតម្រូវការនៃអាហារូបត្ថម្ភទៅតាមដំណាក់កាលនៃវដ្ដជីវិត គឺនៅពេលស្ត្រីមានផ្ទៃពោះ(មុនកើត) ស្ត្រីក្រោយពេលកើតនិងបំបៅដោះ ទារក កុមារភាព (មុនពេលចូលរៀន និងគ្រប់អាយុចូលរៀន) វ័យជំទង់ និងពេញវ័យ។ យើងអាចកែប្រែឱ្យស្ថានភាពអាហារូបត្ថម្ភបានប្រសើរឡើង នៅក្នុងគ្រប់ដំណាក់កាលនៃវដ្ដជីវិត និងបង្ការកង្វះអាហារូបត្ថម្ភបាន។



ឱ្យសិក្ខាកាមទាំងអស់ក្រឡេកមើលដ្យាក្រាមនៃ "អាហារូបត្ថម្ភពេញមួយវដ្តជីវិត"។

*ដំណាក់កាលជីវិត៖*

- មុនពេលកើត៖ -៩ ទៅ ០ខែ
- ទារក៖ ០ ទៅ ១២ខែ
- កុមារតូច៖ ១ ទៅ ១០ឆ្នាំ
- ក្មេងវ័យជំទង់៖ ១០ ទៅ ១៩ឆ្នាំ
- ជនពេញវ័យ៖ ១៩ឆ្នាំឡើង

*ការមានផ្ទៃពោះ និងការផលិតទឹកដោះ៖*

ពេលមានផ្ទៃពោះគឺជាពេលវេលាដ៏សំខាន់ក្នុងជីវិតរបស់ស្ត្រី។ មុនពេលសម្រាល ទារកដែលនៅក្នុងផ្ទៃអាចប្រឈមនឹងការឆ្លងមេរោគអេដស៍។ ទម្ងន់ទារកអាចរងឥទ្ធិពលពីកម្រិតអាហារូបត្ថម្ភរបស់ម្ដាយ។ ប្រសិនបើម្ដាយខ្វះអាហារូបត្ថម្ភ ឬគ្មានអាហារូបត្ថម្ភបម្រុងទុកបានល្អទេ ឬបើមានគំលាតនៃការមានផ្ទៃពោះខ្លី ឬមានផ្ទៃពោះច្រើនដង ទារកក្នុងផ្ទៃមិនអាចលូតលាស់ ឬកើនទម្ងន់បានល្អឡើយ។ ទារកដែលកើតមកមានទម្ងន់ទាប (តិចជាង ២.៥ គីឡូ) អាចមានសុខភាពទន់ខ្សោយជាងទារកដែលកើតមកមានទម្ងន់លើស ២.៥ គីឡូ។ ទារកមិនគ្រប់ទម្ងន់អាចប្រឈមមុខខ្ពស់នឹងអត្រាមរណភាព ឬអាចអាចក្រិន ឬតឿ ដែលបណ្ដាលមកពីកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ ភាពក្រិនដែលកើតឡើងនៅអាយុក្មេងខ្ចី កាត់បន្ថយសមត្ថភាពខួរក្បាល និងអាចទំនងជាបន្តរហូតដល់វ័យជំទង់ និងពេញវ័យ។

*សំនួរ៖* ហេតុអ្វីបានជាអាហារូបត្ថម្ភល្អមានសារៈសំខាន់ចំពោះស្ត្រីមានផ្ទៃពោះ?

*បន្ទាប់មកពន្យល់៖* ដើម្បីលូតលាស់បានល្អ ទារកត្រូវការម្ដាយមានសុខភាពល្អ និងអាហារូបត្ថម្ភគ្រប់គ្រាន់។ ស្ត្រីមានផ្ទៃពោះមានតម្រូវការអាហារូបត្ថម្ភបន្ថែម ដោយសារតែការផ្លាស់ប្តូរក្នុងរាងកាយរបស់គាត់ និងតម្រូវការលូតលាស់របស់ទារកក្នុងផ្ទៃ។ ស្ត្រីមានផ្ទៃពោះទាំងអស់មានតម្រូវការដូចគ្នា នេះមិនថាពួកគេមានឆ្លងមេរោគអេដស៍ ឬអត់នោះទេ។ តម្រូវការថាមពលកើនឡើងដោយសារ៖

- ជំងឺ និងការឆ្លងមេរោគ៖ អ្នករស់នៅជាមួយមេរោគអេដស៍ដែលមានផ្ទៃពោះត្រូវការថាមពលបន្ថែមសម្រាប់ ការលូតលាស់របស់ទារក និងដើម្បីប្រឆាំងទប់ទល់នឹងមេរោគ។ មេរោគឆ្លង ឬជំងឺធ្វើឱ្យមានតម្រូវការថាមពលកើនឡើងបន្ថែមចន្លោះពី ២០–៣០% (ប្រហែល បាយ២ចានចង្កឹះក្នុងមួយថ្ងៃ)
- អាហារូបត្ថម្ភមិនគ្រប់គ្រាន់ ឬការមានផ្ទៃពោះនៅវ័យក្មេង ឬការមានផ្ទៃពោះដែលមានទម្ងន់មិនគ្រប់ ក៏ធ្វើឱ្យរាងកាយមានតម្រូវការអាហារូបត្ថម្ភបន្ថែមដែរ។
- ការងារ និងសកម្មភាពផ្សេងៗ៖ បើស្ត្រីមានផ្ទៃពោះធ្វើការងារច្រើន ឧទាហរណ៍ មើលថែក្មេងតូចៗ និងប្រមូលផលដំណាំ គាត់នឹងមានតម្រូវការថាមពលច្រើន

ជាងស្ត្រីមានផ្ទៃពោះម្នាក់មិនសូវធ្វើសកម្មភាពការងារច្រើន។

យកល្អ មាតាគួរទទួលបានអាហារចម្រុះគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការអាហារូបត្ថម្ភ អំឡុងពេលមានផ្ទៃពោះ។ តម្រូវការកាឡូរីបន្ថែម (២០០–៥០០កាឡូរី/ថ្ងៃ)ក្នុងពេល មានផ្ទៃពោះគឺជារឿងចាំបាច់ ប៉ុន្តែរឹតតែសំខាន់ទៅទៀតគឺអាហារត្រូវមានជីវជាតិចិញ្ចឹម កាន់តែច្រើន។

*ពន្យល់៖* បន្តិចទៀតក្នុងពេល យើងនឹងសិក្សាលម្អិតទៅលើប័ណ្ណរស់នៅប្រកបដោយ សុខភាពល្អលេខ២១ (ការបរិភោគត្រឹមត្រូវនៅពេលមានផ្ទៃពោះ ឬបំបៅដោះកូន)។

*បន្តការធ្វើបទបង្ហាញ៖* តម្រូវការថាមពល ចំពោះស្ត្រីមានផ្ទៃពោះដែលគ្មានផ្ទុកមេរោគ អេដស៍ និងមានទម្ងន់ធម្មតាគឺមានតិចតួចនៅក្នុងត្រីមាសដំបូង ប៉ុន្តែវាមានការកើនឡើង នៅត្រីមាសទីពីរ និងទីបី។ ដូច្នេះ គាត់ត្រូវការថាមពលបន្ថែមដើម្បីឱ្យមានការកើនឡើង ទម្ងន់គ្រប់គ្រាន់ ហើយទារកក្នុងផ្ទៃមានអាហារូបត្ថម្ភគ្រប់គ្រាន់ដើម្បីលូតលាស់ល្អ។

ស្ត្រីបំបៅដោះកូនត្រូវការថាមពលប្រហែលនឹងស្ត្រីមានផ្ទៃពោះនៅក្នុងត្រីមាសទី៣ដែរ។ បើម្តាយមានថាមពលគ្រប់គ្រាន់សម្រាប់បំបៅដោះ វាងនឹងមិនធ្វើឱ្យថាមពលរបស់គាត់ បាត់បង់ច្រើនលើសលប់ពេក។

## អនុសាសន៍អំពីភាពញឹកញាប់ក្នុងការបរិភោគអាហារ សម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូនដែលរស់នៅជាមួយមេរោគអេដស៍៖

| | | **ភាពញឹកញាប់នៃអាហារពេល និងអាហារសម្រន់** |
|---|---|---|
| **ស្ត្រីមានផ្ទៃពោះ** | | អាហារពេល៣ពេល និងអាហាសម្រន់១ដង |
| **ស្ត្រីមានផ្ទៃពោះ រស់នៅជាមួយ មេរោគអេដស៍** | ត្រីមាសទី១ | អាហារពេល៣ពេល និងអាហារសម្រន់២ដង |
| | ត្រីមាសទី២-៣ | អាហារពេល៣ពេល និងអាហារ សម្រន់២ដង ឬយ៉ាងតិច អាហារពេល ៤ពេល |
| **ស្ត្រីមានផ្ទៃពោះ រស់នៅជាមួយ មេរោគអេដស៍ និងមានជំងឺ** | | យ៉ាងតិច អាហារពេល ៤ពេល និង អាហារសម្រន់ ២ដង |
| **ស្ត្រីបំបៅដោះកូន រស់នៅ ជាមួយមេរោគអេដស៍** | | អាហារពេល៣ពេល និងអាហារសម្រន់២ដង ឬយ៉ាងតិច អាហារពេល៤ពេល |
| **ស្ត្រីបំបៅដោះកូន រស់នៅជាមួយ មេរោគអេដស៍ និងមានជំងឺ** | | យ៉ាងតិចអាហារពេល ៤ពេល និង អាហារសម្រន់ ២ដង |

*សួរសិក្ខាកាមថា៖* តើអ្នកនឹងណែនាំឱ្យស្ត្រីបរិភោគអ្វី បើគាត់ត្រូវការអាហារពេល ឬអាហារសម្រន់បន្ថែមក្នុងមួយថ្ងៃ? សរសេរចម្លើយសិក្ខាកាមលើក្តារខៀន។

*ពន្យល់៖* ការបរិភោគ អាហារស្ថាបនារាងកាយ (អាហារសម្បូរប្រូតេអ៊ីន) និងអាហារការពាររាងកាយ (អាហារមានជីវជាតិ និងរ៉ែខនិជខ្ពស់) មានសារៈសំខាន់ណាស់។ ការមានផ្ទៃពោះ និងបំបៅដោះកូនធ្វើឱ្យកើនឡើងនូវតម្រូវការប្រូតេអ៊ីនសម្រាប់ដូច្នេះពួកគាត់ត្រូវការប្រូតេអ៊ីនបន្ថែមប្រហែល១៥%។ បរិមាណបន្ថែមនេះស្មើនឹងប្រូតេអ៊ីន១០ក្រាម ដែលអាចទទួលបានពី៖ សាច់ត្រី/សាច់មាន់/សាច់ជ្រូកចម្អិនរួច១/៤ចានចង្កឹះ ឬតៅហ៊ូ៦ស្លាបព្រាបាយ ឬទឹកដោះគោ/ទឹកសណ្តែក១ចានចង្កឹះ ឬសណ្តែកបាយចម្អិនរួច៣/៤ចាន ឬស៊ុតពីរគ្រាប់ ឬគ្រាប់សណ្តែក១/៣ចានចង្កឹះ។ ជាទូទៅគេអាចបំពេញតម្រូវការប្រូតេអ៊ីនបន្ថែម ដោយគ្រាន់តែបន្ថែមបរិមាណអាហារដែលបរិភោគជាធម្មតា។ ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ពុំមានតម្រូវការប្រូតេអ៊ីនច្រើនជាងស្ត្រីធម្មតាទេ។

*សំនួរ៖* តើពួកគាត់មានតម្រូវការអ្វីផ្សេងទៀតទេ?

*ពន្យល់៖* ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូនមានការកំណើនតម្រូវការជីវជាតិ (មីក្រូសារជាតិ) មួយចំនួនតូចសម្រាប់ការវិវឌ្ឍន៍របស់ទារកក្នុងផ្ទៃ។ ការបរិភោគអាហារចម្រុះច្រើនប្រភេទនឹងអាចបំពេញតម្រូវការជីវជាតិនេះបាន។ ស្ត្រីដែលគ្មានលទ្ធភាពក្នុងការបិភោគអាហារចម្រុះនឹងប្រឈមនឹងកង្វះអាហារូបត្ថម្ភ។ សម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន កាល់ស្យូម ជាតិដែក ជាតិផូស្វាត អ៊ីយ៉ូដ ស័ង្កសី និងជីវជាតិអា គឺជាជីវជាតិសំខាន់ៗ ដែលអាចទទួលបានមកពីប្រភពដូចនៅក្នុងតារាងបន្ទាប់។



| ជីវជាតិ | ប្រភព |
|---|---|
| កាល់ស្យូម | ត្រីល្អិតមានឆ្អឹង កំពឹស បង្កង កាពិ ប្រហុក ទឹកដោះគោ តៅហ៊ូ ឬសណ្ដែកដី យ៉ាងតិច៣ពេលក្នុងមួយថ្ងៃ (ឧ. បរិភោគទឹកដោះគោ៣កែវ/ថ្ងៃ) |
| ជាតិដែក | សាច់ត្រី ខ្ទៅខ្យង ស៊ុត បន្លែសន្លឹកពណ៌បៃតង។ ក្រៅពីនេះ ជាធម្មតាស្ត្រីត្រូវការជាតិដែកបន្ថែម ដើម្បីចៀសវាងភាពស្លេកស្លាំង ជាពិសេសបើមិនបានបរិភោគសាច់ពណ៌ក្រហមទៀងទាត់ |
| ជាតិផូឡាត | បន្លែស្លឹកបៃតងគ្រាប់ស្រូវសាលី ផ្លែឈើ នំប៉័ង អាហារដែលមានជីវជាតិបន្ថែម។ ក្រៅពីនេះ ជាទូទៅស្ត្រីត្រូវការជីវជាតិផូឡាតបន្ថែម ដើម្បីចៀសវាងបញ្ហាចំពោះទារកក្នុងផ្ទៃ |
| អ៊ីយ៉ូត | មានក្នុងអំបិលអ៊ីយ៉ូដ បន្លែ។ បន្ថែមអំបិលអ៊ីយ៉ូដតិចៗជាប្រចាំទៅក្នុងអាហារនឹងអាចបំពេញតាមតម្រូវការអ៊ីយ៉ូតគ្រប់គ្រាន់ |
| ស័ង្កសី | សាច់ត្រី សាច់ ផ្លែឈើ និងបន្លែអន្លក់ |
| ជីវជាតិអា | ល្ពៅ ស្វាយ ទឹកដោះគោ ស៊ុត ថ្លើម បន្លែស្លឹកបៃតង និងការ៉ុត |







**កំណត់សម្គាល់៖**

ស្ត្រីមានផ្ទៃពោះ និងទារកងាយរងគ្រោះដោយភាពស្លេកស្លាំងដោយសារកង្វះជាតិដែក ហើយមេរោគអេដស៍រឹតតែបង្កើនភាពងាយរងគ្រោះនេះ។ អាហារដែលបានពីសាច់សត្វមាន សារៈសំខាន់សម្រាប់ទទួលទានអំឡុងពេលមានផ្ទៃពោះ ព្រោះវាជាប្រភពអាហារដែលសម្បូរជាតិដែក។ ជាតិដែកដែលបានមកពីសាច់សត្វជ្រាបចូលបានយ៉ាងល្អទៅក្នុងរាងកាយ។ វាកាត់បន្ថយភាពស្លេកស្លាំង ឬកង្វះឈាមក្រហម។ ដូច្នេះ វាមានសារៈសំខាន់ណាស់ នៅក្នុងការបង្កើនការបរិភោគអាហារសាច់សត្វ។ បន្លែស្លឹក បៃតង និងសណ្ដែកមានផ្ទុកជាតិដែក ប៉ុន្តែជាតិដែកនេះអាចមិនជ្រាបចូលបានល្អក្នុងរាងកាយទេ។ ទោះជាយ៉ាងនេះក្ដី គេអាចបង្កើនការជ្រាបជាតិដែកតាមរយៈការបរិភោគអាហារមានជាតិវីតាមីនសេ ដូចជាប៉េងប៉ោះ ឬក្រូចឆ្មា។

អំឡុងពេលមានផ្ទៃពោះ ស្ត្រីត្រូវការជីវជាតិវីតាមីនអា បន្ថែម ប៉ុន្តែត្រូវប្រុងប្រយ័ត្នកុំទទួលទានជីវជាតិអាហួសកម្រិត ដែលអាចបង្កភាពមិនប្រក្រតីចំពោះទារក។ បើខ្វះជាតិវីតាមីនអា វិធីដែលល្អបំផុតក្នុងការស្រូបយកជីវជាតិនេះគឺតាមរយៈការទទួលទានអាហារ។

ការផ្ដល់ជីវជាតិបន្ថែមដល់ស្ត្រីមានផ្ទៃពោះដែលរស់នៅជាមួយមេរោគអេដស៍គួរតែធ្វើឡើងតាមបទដ្ឋានជាតិស្ដីពីការថែទាំមុនសម្រាលសម្រាប់ស្ត្រីមានផ្ទៃពោះទាំងអស់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល អនុសញ្ញាស្ដីពីការគ្រប់គ្រងមាតុភាពគ្មានគ្រោះថ្នាក់ក្នុងគ្លីនិក ដែលរៀបចំឡើងដោយក្រសួងសុខាភិបាល ព្រមទាំងគោលការណ៍ណែនាំ និងគោលនយោបាយជាតិស្ដីអំពីអាហារបន្ថែមមីក្រូសារជាតិ ដើម្បីគាំពារ និងត្រួតពិនិត្យកង្វះអាហារូបត្ថម្ភនៅកម្ពុជា ដែលរៀបចំឡើងដោយកម្មវិធីជាតិអាហារូបត្ថម្ភ ឆ្នាំ២០១១។

*សំណួរ៖* ហេតុអ្វីបានជាការកើនទម្ងន់មានសារៈសំខាន់អំឡុងពេលមានផ្ទៃពោះ?

ស្ត្រីមានផ្ទៃពោះម្នាក់ត្រូវការកើនទម្ងន់អំឡុងពេលមានផ្ទៃពោះ ដើម្បី៖

- ការលូតលាស់ និងការវិវឌ្ឍន៍របស់ទារកក្នុងផ្ទៃ
- ការផ្លាស់ប្តូរនៃរាងកាយរបស់ម្តាយអំឡុងពេលមានផ្ទៃពោះ

របបអាហារគ្រប់គ្រាន់ធ្វើឱ្យកើនទម្ងន់បានល្អ អាស្រ័យទៅលើសន្ទស្សន៍ម៉ាស់រាងកាយរបស់ម្តាយ។ បើម្តាយមានទម្ងន់មិនគ្រប់គ្រាន់ កំណើនទម្ងន់អាចលើស១៦គីឡូក្រាមអំឡុងពេលមានផ្ទៃពោះ។ ប្រសិនបើម្តាយលើសទម្ងន់ កំណើនទម្ងន់អាចតិចជាង ៨គីឡូក្រាម។ កំណើនទម្ងន់របស់ស្ត្រីអំឡុងពេលមានផ្ទៃពោះអាស្រ័យទៅលើទម្ងន់មុនពេលមានផ្ទៃពោះរបស់គាត់។ សម្រាប់ស្ត្រីដែលមានសុខភាពល្អ កំណើនទម្ងន់ជាមធ្យមក្នុងអំឡុងពេលមានផ្ទៃពោះ គឺនៅចន្លោះ១២–១៥គីឡូក្រាម។

ស្ត្រីមានផ្ទៃពោះដែលកើនទម្ងន់មិនគ្រប់គ្រាន់ ច្រើនបង្កើតបានទារកមិនគ្រប់ទម្ងន់។ ទារកដែលកើតមិនគ្រប់ទម្ងន់ មិនអាចលូតលាស់បានល្អ និងងាយរងគ្រោះដោយសារការឆ្លងរោគ និងកង្វះអាហារូបត្ថម្ភ ជាងទារកដែលមានទម្ងន់ធម្មតា។

កំណើនទម្ងន់ និងអាហារូបត្ថម្ភល្អធ្វើឱ្យទារកលូតលាស់ និងវិវឌ្ឍន៍បានធម្មតា កើតគ្រប់ខែ និងមានទម្ងន់ល្អធម្មតា (ចន្លោះ២.៥ ទៅ ៤គីឡូក្រាម)។ ក្រៅពីនេះ ម្តាយនឹងអាចមានលទ្ធភាពទទួលបានវិធីបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន។

តារាងខាងក្រោមនេះបង្ហាញនូវកំណើនទម្ងន់ជាទូទៅក្នុងអំឡុងពេលមានផ្ទៃពោះ ដោយផ្អែកលើទម្ងន់មុនមានផ្ទៃពោះ។ វាគ្រាន់តែជាព័ត៌មានទូទៅប៉ុណ្ណោះ។ ស្ត្រីមានផ្ទៃពោះគួរតែពិនិត្យសុខភាពឱ្យបានទៀងទាត់ជាមួយអ្នកជំនាញសុខភាព។

| ទម្ងន់មុនពេលមានផ្ទៃពោះ<br>សន្ទស្សន៍ម៉ាស់រាងកាយ (BMI) | ការឡើងទម្ងន់សរុប |
|---|---|
| ទម្ងន់មិនគ្រប់ (ក្រោមជាង ១៨,៥) | ១២,៥ ទៅ ១៨ គីឡូក្រាម |
| ទម្ងន់ធម្មតា (១៨,៦ ទៅ ២៤,០) | ១២,៥ ទៅ ១៦ គីឡូក្រាម |
| លើសទម្ងន់ (២៥,០ ទៅ ២៩,៩) | ៧ ទៅ ១១,៥ គីឡូក្រាម |
| ធាត់ជ្រុល (លើស ឬស្មើ ៣០,០) | ៤,៥ ទៅ ៩ គីឡូក្រាម |

*ប្រភព៖ កំណើនទម្ងន់អំឡុងពេលមានផ្ទៃពោះ៖ សេចក្តីណែនាំរបស់ វិទ្យាស្ថានវេជ្ជសាស្ត្រ* (IOM) ២០០៩។

*បន្តការធ្វើបទបង្ហាញ៖* ស្ត្រីមានផ្ទៃពោះប្រឈមនឹងគ្រោះថ្នាក់ខ្ពស់នឹងជំងឺដែលបណ្តាលមកពីអាហារ។ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នេះ គួរមានវិធានការការពារត្រឹមត្រូវ។ ស្ត្រីមានផ្ទៃពោះគួរតែចៀសវាងទទួលទានសាច់ ត្រី និងស៊ុតដែលឆៅ ឬមិនឆ្អិនល្អ។ ទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះ គួរតែរម្ងាប់មេរោគ ឬកម្តៅតាមដែលអាចធ្វើទៅបាន។

## សកម្មភាពបំផុសគំនិត

> **កំណត់សម្គាល់**
>
> ចម្លើយត្រឹមត្រូវមានដូចជា៖
>
> » ពិសារទឹកស្អាត/ដាំពុះ
>
> » លាងដៃនឹងសាប៊ូ
>
> » លាងសម្អាតផ្លែឈើ និងបន្លែ
>
> » រៀបចំចម្អិនម្ហូបអាហារដែលមានប្រភពពីសត្វឱ្យហួតចត់ និងឆ្អិនល្អ
>
> » ចៀសវាងទទួលទានសាច់ ត្រី និងស៊ុតឆៅ ឬមិនឆ្អិនល្អក្នុងពេលមានផ្ទៃពោះ។

*សំនួរ៖* "តើការអនុវត្តន៍រៀបចំអាហារណាខ្លះដែលអ្នកគួរតែណែនាំដល់ស្ត្រីមានផ្ទៃពោះដើម្បីចៀសវាងជំងឺបណ្តាលមកពីអាហារ"?

កត់ត្រាចម្លើយលើក្តារខៀន ឬផ្ទាំងក្រដាស រួចពន្យល់បន្ថែម។

*ពន្យល់៖* ក្រៅពីការបរិភោគត្រឹមត្រូវ មានកត្តាដទៃទៀតដែលស្ត្រីគួរចៀសវាងក្នុងអំឡុងពេលមានផ្ទៃពោះ និងបំបៅដោះកូន។

- ការជក់បារី៖ ការជក់បារីនៅពេលមានផ្ទៃពោះធ្វើឱ្យម្តាយនិងកូននៅក្នុងផ្ទៃប្រឈមនឹងបញ្ហាសុខភាពខ្ពស់ ដូចជា រលូត ឬកូនកើតមិនគ្រប់ខែ។ ម្តាយដែលជក់បារីបង្កើនឱកាសខ្ពស់ទ្វេរដង ក្នុងការបង្កើតកូនមិនគ្រប់ទម្ងន់។
- ជាតិស្រា៖ ការប្រើប្រាស់ជាតិស្រាច្រើនហួសប្រមាណនៅពេលមានផ្ទៃពោះបង្កគ្រោះថ្នាក់ដល់ទារកនៅក្នុងផ្ទៃ ជាពិសេសនៅក្នុងត្រីមាសដំបូង។ ជាទូទៅគេណែនាំឱ្យស្ត្រីមានផ្ទៃពោះតមគ្រឿងស្រវឹង ព្រោះពុំមានគោលការណ៍ណែនាំអំពីការកំណត់ការប្រើប្រាស់ជាតិស្រវឹងនៅក្នុងកម្រិតសុវត្ថិភាពនោះទេ។ គេទទួលស្គាល់ថា ស្ត្រីមានដែលមានផ្ទៃពោះច្រើនខែ អាចទទួលទានគ្រឿងស្រវឹងក្នុងបរិមាណតិចតួច និងអាចមិនបង្កឱ្យមានគ្រោះថ្នាក់។
- ថ្នាំ៖ ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូនដោយទឹកដោះគួរត្រូវជៀសវាងថ្នាំញៀន ឬថ្នាំខុសច្បាប់ផ្សេងៗ។ ក្រៅពីនេះ រាល់ការប្រើប្រាស់ឱសថ ត្រូវពិនិត្យមើលការណែនាំ និងប្រាកដថា វាមិនប៉ះពាល់ដល់សុខភាពអំឡុងពេលមានផ្ទៃពោះ។ ក្នុងអំឡុងពេលបំបៅដោះកូន ថ្នាំអាចជ្រាបចូលទៅក្នុងខ្លួនទារកតាមរយៈទឹកដោះដែលអាចធ្វើឱ្យទារកញៀននឹងថ្នាំនោះ។
- ជាតិកាហ្វេអ៊ីន៖ ស្ត្រីមានផ្ទៃពោះគួរទទួលទានកាហ្វេតិចជាងបួនពែងក្នុងមួយថ្ងៃ ពីព្រោះការទទួលទានជាតិកាហ្វេអ៊ីនហួសប្រមាណធ្វើឱ្យប៉ះពាល់ដល់ ការលូតលាស់របស់ទារកក្នុងផ្ទៃ។ កាហ្វេអ៊ីនក៏អាចប៉ះពាល់ដល់ដំណេករបស់ទារកដែលបៅដោះម្តាយផងដែរ។

## ទារក និងកុមារអាយុពី០-២៤ខែ

*ពន្យល់៖* ដំណើរជីវិតរបស់ទារករីកលូតលាស់ចាប់តាំងពីពេលកើត រហូតដល់អាយុ ២២ខែ។ ក្នុងករណីដែលម្តាយជ្រើសរើសយកវិធីបំបៅកូនដោយទឹកដោះម្តាយ ទារកនឹងប្រឈមនឹងការឆ្លងមេរោគអេដស៍ក្នុងកម្រិតទាប។ ការឆ្លងមេរោគអេដស៍តាមរយៈទឹកដោះម្តាយគឺជាគ្រោះថ្នាក់មួយ ក៏ប៉ុន្តែគេអាចកាត់បន្ថយគ្រោះថ្នាក់នេះបានច្រើន ប្រសិនបើម្តាយបំបៅដោះកូនសុទ្ធ និងប្រើប្រាស់ ឱសថប្រឆាំងនឹងមេរោគអេដស៍។

ដូចដែលយើងបានពិភាក្សាខាងដើម តម្រូវការថាមពលរបស់ទារកមានកម្រិតខ្ពស់ ព្រោះនេះជាពេលដែលទារកមានការរីកលូតលាស់ឆាប់រហ័ស។ តម្រូវការថាមពលខ្ពស់ បង្កើនឱ្យមានការប្រឈមកង្វះអាហារូបត្ថម្ភនៅក្នុងវ័យនេះ។

ទារកភាពគឺជាដំណាក់កាលមួយដែលទារក ងាយរងគ្រោះដោយសារជំងឺ និងមេរោគផ្សេងៗដែលបណ្តាលមកពីបរិយាកាសដែលមានមេរោគ និងផ្តល់អាហារដោយគ្មានសុវត្ថិភាព។ ការផ្តល់អាហារដែលគ្មានសុវត្ថិភាពអាចបង្កឱ្យទារករាករូស ដែលជាបញ្ហាចម្បងបណ្តាលឱ្យទារកស្លាប់ទូទាំងពិភពលោក។

គេអាចដឹងថាទារកមានមេរោគអេដស៍ ប្រសិនបើមានចេញរោគសញ្ញានៃមេរោគ ហើយម្តាយទារកត្រូវបានគេដឹងថាមានផ្ទុកមេរោគអេដស៍។ ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍(ART) អាចនឹងមិនមានសម្រាប់ពួកគេ។ កុមារអាចមានជំងឺរាករូស និងជំងឺឆ្លងដោយសារការផ្តល់អាហារជំនួស ដោយគ្មានសុវត្ថិភាព។ អាហារូបត្ថម្ភមិនគ្រប់គ្រាន់ក្នុងអំឡុងពេល១២ខែដំបូង អាចធ្វើឱ្យកុមារខ្វះអាហារូបត្ថម្ភ និងបង្អាក់ដល់ការលូតលាស់(គ្រិន)។ នៅពេលអាយុប្រាំមួយខែ ត្រូវផ្តល់អាហារបន្ថែមដែលមានជាតិដែកខ្ពស់ បន្ថែមពីលើទឹកដោះម្តាយ និងទឹកដោះគោម្សៅ។ កុមារដែលមានរបបអាហារមិនគ្រប់គ្រាន់ច្រើនខ្វះជាតិដែក។

## ការផ្តល់អាហារដល់ទារក

*ពន្យល់៖* ការផ្តល់អាហារដល់ទារកមានឥទ្ធិពលដល់ការស្លាប់រស់របស់ទារក និងកុមារ។ ការផ្តល់អាហារដល់ទារក និងកុមារតូចៗឱ្យបានល្អគឺជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតសុខភាព អាហារូបត្ថម្ភ និងការរីកលូតលាស់របស់កុមារ ប៉ុន្តែកុមារភាគច្រើនមិនបានទទួលការផ្តល់អាហារត្រឹមត្រូវឡើយ។ គោលការណ៍ណែនាំជាសកលស្តីអំពីការផ្តល់អាហារដល់ទារក និងកុមារចែងថា៖

- បំបៅដោះទារកក្នុងពេលមួយម៉ោងបន្ទាប់ពីកើត
- បំបៅដោះសុទ្ធតែមួយមុខគត់ ចាប់តាំងពីពេលកើតរហូតដល់អាយុ៦ខែ

- ផ្ដល់អាហារបន្ថែមដល់កុមារដែលមានអាយុចាប់ពី៦ខែឡើងទៅ
- ត្រូវបន្តបំបៅដោះម្ដាយរហូតដល់អាយុ២ឆ្នាំ ឬលើសពីនោះ

📄 កំណត់សម្គាល់

ការបំបៅកូនដោយទឹកដោះសុទ្ធមានន័យថា៖

» ទារកត្រូវទទួលទានទឹកដោះម្ដាយ

» ទារកអាចទទួលផងដែរនូវ ថ្នាំបន្តក់ ថ្នាំទឹក (ជីវជាតិផ្សេងៗ ជាតិខនិជ ថ្នាំពេទ្យ)

» ទារកមិនគួរទទួល អ្វីផ្សេងក្រៅពីនេះទេ។

អង្គការសុខភាពពិភពលោកណែនាំថា ម្ដាយគ្រប់រូប មិនថាពួកគេមានផ្ទុកមេរោគអេដស៍ឬក៏អត់ ត្រូវបំបៅកូនដោយទឹកដោះម្ដាយសុទ្ធ ដែលមានន័យថា មិនត្រូវផ្ដល់សារធាតុរាវ ឬអាហារដទៃ ដល់ទារកក្នុងអំឡុងពេល៦ខែដំបូងឡើយ។ បន្ទាប់ពីរយៈពេលប្រាំមួយខែ ទារកអាចចាប់ផ្ដើមទទួលអាហារបន្ថែមក្រៅពីទឹកដោះម្ដាយបាន។ ម្ដាយគ្រប់រូបដែលគ្មានផ្ទុកមេរោគអេដស៍គប្បីត្រូវបំបៅដោះកូនរហូតដល់ទារកមានអាយុ២ឆ្នាំ ឬច្រើនជាងនេះ។ ការបំបៅដោះសុទ្ធតែមួយមុខគត់ផ្ដល់អត្ថប្រយោជន៍លើផ្នែកសារជាតិចិញ្ចឹម សុខភាព និងភាពស្និទ្ធស្នាលដល់ទារក។

## សកម្មភាពបំផុសគំនិត

*សំណួរ៖* "តើការបំបៅដោះកូនមានអត្ថប្រយោជន៍អ្វីខ្លះ"? បំផុសគំនិតអំពីអត្ថប្រយោជន៍នៃការបំបៅដោះ។ ព្យាយាមបំផុសគំនិតសំខាន់ៗដូចខាងក្រោម៖

| ទឹកដោះម្ដាយ | ការបំបៅដោះម្ដាយដល់កូន |
|---|---|
| គឺជាសារជាតិចិញ្ចឹមដ៏ល្អឥតខ្ចោះ៖ វាផ្ដល់សារជាតិចិញ្ចឹមគ្រប់ប្រភេទដែលទារកត្រូវការ | បង្កើតទំនាក់ទំនងជិតស្និទ្ធរវាងម្ដាយ និងទារក |
| ងាយស្រួលរំលាយ មានប្រសិទ្ធភាពក្នុងការស្រូបយកជីវជាតិ | ជួយឱ្យទារកមានអារម្មណ៍កក់ក្ដៅ និងរីករាយ |
| ការពារប្រឆាំងនឹងការឆ្លងរោគ និងជំងឺផ្សេងៗ | ការពារសុខភាពមាតា |
| មិនចំណាយថវិកា<br>មានអនាម័យអាចប្រើបានភ្លាម | ជួយពន្យាគំលាតនៃការមានផ្ទៃពោះពីកូនមួយទៅកូនមួយទៀត |
| មានជាតិទឹកគ្រប់គ្រាន់ ទោះបីជាពេលអាកាសធាតុក្ដៅក៏ដោយ | |

### ពិភាក្សាអំពីគ្រោះថ្នាក់នៃការបំបៅដោះ និងបញ្ហាប្រឈម

- ប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្ដាយទៅទារក៖ ទារកអាចឆ្លងមេរោគអេដស៍តាមរយៈការបំបៅដោះម្ដាយ។ ទោះជាយ៉ាងនេះក៏ដោយ បន្សំនៃការបំបៅដោះសុទ្ធតែមួយមុខគត់ និងការប្រើប្រាស់សេវាព្យាបាលប្រឆាំងនឹងមេរោគអេដស៍ អាចកាត់បន្ថយគ្រោះនៃការឆ្លងនេះបាន។
- ត្រូវបំបៅទឹកដោះម្ដាយសុទ្ធសម្រាប់រយៈពេល៦ខែដំបូង មិនត្រូវបំបៅចម្រុះ (ឧទាហរណ៍៖ ទឹកដោះម្ដាយ និងទឹកដោះគោ ឬអាហារក្នុងពេលតែមួយទេ)
- ប្រសិនបើម្ដាយឈឺខ្លាំង អាចនឹងមានការលំបាកក្នុងការបំបៅដោះកូន។

## *ការផ្ដល់អាហារដល់ទារកក្នុងបរិបទមានផ្ទុកមេរោគអេដស៍*

> ពាក្យសំខាន់ៗ
>
> » *ការបំបៅដោះសុទ្ធ* គឺការផ្ដល់ទឹកដោះម្ដាយតែមួយមុខគត់ និងមិនទទួលវត្ថុរាវ ឬរឹងផ្សេងទៀត សូម្បីតែទឹក លើកលែងតែដំណក់ថ្នាំជីវជាតិ ជាតិខនិជ ឬថ្នាំពេទ្យ។
>
> » *ការផ្ដល់អាហារជំនួស* ជាការផ្ដល់អាហារដោយមិនឱ្យទារកបៅទឹកដោះម្ដាយ ជាធម្មតាគឺបៅទឹកដោះគោម្សៅ។
>
> » *ការផ្ដល់អាហារចម្រុះ* ជាការផ្ដល់ទឹកដោះម្ដាយ និងអាហារ ឬសារធាតុរាវផ្សេងៗ រួមទាំងទឹកដោះគោម្សៅ ទឹកដោះសត្វ ឬទឹក។ ការផ្ដល់អាហារចម្រុះមុនអាយុ៦ខែ បង្កឱកាសខ្ពស់ក្នុងការចម្លងមេរោគអេដស៍ពីម្ដាយដែលមានផ្ទុកមេរោគអេដស៍ទៅកូន។

### ចាប់ពីពេលកើតរហូតដល់អាយុ៦ខែ

### ការបំបៅដោះសុទ្ធ

*ពន្យល់៖* គោលការណែនាំជាតិស្ដីពី "ការបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន" (របស់ក្រសួងសុខាភិបាលកម្ពុជា ២០១១) ណែនាំ និងលើកទឹកចិត្តដល់ស្ត្រីគ្រប់រូប ទោះផ្ទុក ឬមិនផ្ទុករោគអេដស៍ ឱ្យបំបៅដោះម្ដាយសុទ្ធតែមួយមុខគត់ដល់ទារកសម្រាប់រយៈពេល៦ខែដំបូង។ ម្ដាយបំបៅដោះកូន ដែលមានផ្ទុកមេរោគអេដស៍គួរតែប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍ (ARV) រហូតដល់មួយសប្ដាហ៍បន្ទាប់ពីបញ្ឈប់ការបំបៅដោះពេញលេញ ដើម្បីបង្ការការឆ្លងមេរោគអេដស៍តាមរយៈទឹកដោះ។ ទារកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ទាំងអស់ គួរតែទទួលបានឱសថប្រឆាំងមេរោគអេដស៍ជាប្រចាំរាល់ថ្ងៃ ចាប់តាំងពីពេលកើតរហូតដល់អាយុ៦សប្ដាហ៍ ទោះជាម្ដាយជ្រើសរើសយកវិធីបំបៅបែបណាក៏ដោយ។

អត្រានៃការចម្លងពីម្ដាយទៅកូន ដោយសារការបំបៅដោះម្ដាយ ត្រូវបានគេប៉ាន់ស្មានថាមានជាទូទៅប្រហែលជា៥ទៅ២០% ដោយវាមានកត្តាជះឥទ្ធិពលជាច្រើន។ គេមិនអាចប៉ាន់ស្មានអំពីគ្រោះថ្នាក់នៃការឆ្លងពិតប្រាកដទៅលើករណីបុគ្គលម្នាក់ៗឡើយ។ កត្តាដែលធ្វើឱ្យមានការកើនឡើងនូវគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍អំឡុងពេលបំបៅដោះកូនរួមមាន៖

- កម្រិតអាហារូបត្ថម្ភរបស់ម្ដាយខ្សត់ខ្សោយ (កង្វះអាហារូបត្ថម្ភ)
- អត្រាផ្ទុកមេរោគរបស់ម្ដាយនៅពេលបំបៅដោះ៖ ម្ដាយដែលមានកម្រិតផ្ទុកមេរោគ

កាន់តែខ្ពស់អាចបង្កើនគ្រោះថ្នាក់កាន់តែខ្លាំងក្នុងការចម្លងមេរោគអេដស៍តាមរយៈទឹកដោះ។ ម្ដាយដែលជ្រើសរើសប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍តែងមានកម្រិតផ្ទុកមេរោគអេដស៍ទាប ដូច្នេះ គ្រោះថ្នាក់ក្នុងការចម្លងពីម្ដាយទៅកូនក៏មានកម្រិតទាបដែរ។

- រយៈពេលនៃការបំបៅដោះកូន៖ ម្ដាយបំបៅដោះកូនកាន់តែយូរ គ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍កាន់តែខ្ពស់។ ការស្រាវជ្រាវខ្លះបង្ហាញថាគ្រោះថ្នាក់នេះកើនឡើងខ្ពស់ក្រោយរយៈពេល៦ខែ។
- ការបំបៅការបំបៅចំរុះ (បំបៅដោះម្ដាយ រួមជាមួយការបំបៅជំនួស) គឺជាកត្តាដ៏សំខាន់បំផុតមួយដែលបង្កើនគ្រោះថ្នាក់នៃការចម្លងមេរោគ។
- បូសដោះ (ខ្ទុះកើតមានបណ្ដាលមកពីមេរោគ) ក្បាលដោះដាច់រលាត់ (ប្រេះ) និងរោគរលាកដោះ (រលាកញឹកញាប់ បង្កឱ្យកើតរោគឆ្លង) សុទ្ធតែជាឱកាសនៃការបញ្ជូនឈាម និងផ្លាស់ស្នាដែលមានមេរោគអេដស៍កម្រិតខ្ពស់
- ម្ដាយដែលមានជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ មានប្រព័ន្ធការពាររាងកាយខ្សោយ និងងាយឆ្លងរោគផ្សេងៗ
- ជំងឺកើតនៅលើមាត់ទារក ដូចជា ផ្សិត (ជ្រាំង) និងពងបែកក្នុងមាត់ អាចបង្កឱកាសចម្លងមេរោគនៅក្នុងទឹកដោះម្ដាយ ទៅក្នុងឈាមកុមារដោយផ្ទាល់។

*ការពិភាក្សាដោយចំហ៖* សួរសំនួរថា "តើអ្នកគិតថា អ្វីខ្លះជាឧបសគ្គចំពោះការបំបៅដោះម្ដាយសុទ្ធតែមួយមុខគត់ នៅក្នុងប្រទេសកម្ពុជា"?

សម្របសម្រួលការពិភាក្សា និងសង្ខេបខ្លឹមសារ។

## ការផ្ដល់អាហារជំនួស

*ពន្យល់៖* ឥឡូវយើងនឹងនិយាយអំពីការផ្ដល់អាហារជំនួស។ ម្ដាយរស់នៅជាមួយមេរោគអេដស៍ដែលមិនបំបៅកូនដោយទឹកដោះខ្លួន គួរតែផ្ដល់នូវទឹកដោះគោម្សៅដែលផលិតតាមស្តង់ដាអន្តរជាតិ ទៅឱ្យទារកដែលគ្មានមេរោគអេដស៍ ឬទារកដែលមិនដឹងស្ថានភាពច្បាស់ អាស្រ័យទៅតាមលក្ខខណ្ឌ។ មិនត្រូវផ្ដល់អាហារជំនួសដោយលាយជាមួយទឹកដោះគោឆៅ ទឹកសណ្ដែក ឬទឹកដោះគោខាប់ឡើយ។ វាមានសារៈសំខាន់ណាស់ ត្រូវបំបៅដោយទឹកដោះគោម្សៅសុទ្ធសម្រាប់ ៦ខែដំបូង ចៀសវាងការផ្ដល់អាហារចម្រុះ មិនត្រូវលាយការបំបៅដោះ ឬបន្ថែមអាហារដទៃឡើយ។ បើជ្រើសរើសយកការផ្ដល់អាហារជំនួស មិនត្រូវចាប់ផ្ដើមបំបៅដោះម្ដាយឡើងវិញឡើយ។

ដើម្បីផ្ដល់អាហារដោយសុវត្ថិភាពសម្រាប់ទារកដោយប្រើម្សៅទឹកដោះគោ ម្ដាយ ឬអ្នកថែទាំត្រូវគោរពតាមលក្ខខណ្ឌខាងក្រោម៖

- ត្រូវធានាឱ្យមានទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងក្នុងសហគមន៍ និង

- ត្រូវផ្តល់ទឹកដោះគោម្សៅឱ្យបានគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ការលូតលាស់ និងការវិវឌ្ឍន៍របស់ទារក និង
- ត្រូវរៀបចំទឹកដោះគោម្សៅឱ្យដោយសុវត្ថិភាព មានអនាម័យ និងគ្រប់គ្រាន់ជាប្រចាំ ដើម្បីចៀសវាងជំងឺរាករូស និងកង្វះអាហារូបត្ថម្ភ និង
- ឱ្យទារកបៅទឹកដោះគោម្សៅសុទ្ធក្នុងរយៈពេល៦ខែដំបូង ហើយគ្រួសារទាំងមូលត្រូវយល់ព្រមគាំទ្រអនុវត្តតាមវិធី នេះ និង
- អាចទទួលបានវិធីថែទាំសុខភាពសមស្របសម្រាប់កុមារ។

ការផ្តល់អាហារជំនួសដោយប្រើទឹកដោះគោម្សៅអាចប្រឈមនឹងការបង្កឱ្យមានជំងឺរាករូស ជំងឺដង្ហើម និងកង្វះអាហារូបត្ថម្ភ ប្រសិនបើមិនបានរៀបចំត្រឹមត្រូវ និងប្រកបដោយអនាម័យ។ ការផ្តល់អាហារជំនួសមិនបង្កឱ្យមានការប្រឈមនឹងការឆ្លងមេរោគអេដស៍ឡើយ។

## គុណវិបត្តិនៃការផ្តល់អាហារជំនួស៖

- ទឹកដោះគោម្សៅមិនមានអង្គបដិបក្ខដែលអាចការពារទារកពីការឆ្លងរោគឡើយ
- ការរើសអើង
- ត្រូវការពេលវេលា ចំណេះដឹង និងជំនាញគ្រប់គ្រាន់ដើម្បីរៀបចំទឹកដោះគោម្សៅ
- ត្រូវបន្តទិញទឹកដោះគោម្សៅឱ្យមានជាប់ជានិច្ច
- អាចប្រឈមនឹងជំងឺ
- តម្លៃថ្លៃ

## កុមារអាយុចាប់ពី៦ខែឡើងទៅ

បន្ទាប់មក ពន្យល់អំពីអនុសាសន៍របស់ "គោលការណ៍ណែនាំជាតិស្តីពី ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន"៖

- ម្តាយរស់នៅជាមួយមេរោគអេដស៍ដែលមានទារកផ្ទុកមេរោគអេដស៍ (HIV DNA PCR Test Positive) គួរណែនាំឱ្យផ្តល់អាហារបន្ថែមដល់ ទារក និងបន្តបំបៅដោះកូនរហូតដល់កូនមានអាយុ ២៤ខែ ឬលើសពីនោះ
- ម្តាយរស់នៅជាមួយមេរោគអេដស៍ដែលមានទារកមិនផ្ទុកមេរោគអេដស៍ (HIV DNA PCR Test Negative) ឬមិនបានដឹងថាមានផ្ទុកមេរោគអេដស៍ គួរណែនាំឱ្យផ្តល់អាហារបន្ថែម និងបន្តបំបៅដោះកូនរហូតដល់កូនមានអាយុ ១២ខែ
- នៅក្នុងប្រទេសកម្ពុជា កុមារភាគច្រើនលូតលាស់បានល្អចាប់ពីកើតរហូតដល់អាយុ៦ខែ ព្រោះពួកគេទទួលបានទឹកដោះម្តាយច្រើន។ ប៉ុន្តែបន្ទាប់ពីអាយុ៦ខែ កុមារភាគច្រើនមិនលូតលាស់បានល្អដូចមុនឡើយ ព្រោះពួកគេមិនទទួលបានអាហារបន្ថែមសមស្រប និងគ្រប់គ្រាន់។ ទឹកដោះម្តាយនៅតែមានសារៈសំខាន់

ខ្លាំង ព្រោះសារជាតិចិញ្ចឹមនៅក្នុងទឹកដោះអាចជួយពួកគេក្នុងការលូតលាស់ និងប្រឆាំងជំងឺផ្សេងៗ។

## សកម្មភាពបំផុសគំនិត៖



បង្ហាញសិក្ខាកាមនូវរូបភាពនៃការលូតលាស់របស់ដើមស្រូវ។ ប្រសិនបើមានការលំបាកក្នុងការបង្ហាញ អ្នកសម្របសម្រួលអាចគូសរូបភាពនេះឱ្យធំៗនៅលើក្រដាសផ្ទាំងធំ។

*សំណួរ៖* តើអ្វីដែលធ្វើឱ្យដើមស្រូវលូតលាស់បានខ្ពស់?



សរសេរចម្លើយទាំងអស់លើក្រដាសផ្ទាំងធំ (ទឹក ជី ពន្លឺព្រះអាទិត្យ ការការពារពីសត្វ ស្មៅ និងរុក្ខជាតិឥតប្រយោជន៍ផ្សេងៗ ។ល។)

ដើមស្រូវដែលលូតលាស់កាន់តែខ្ពស់ល្អនឹងផ្តល់នូវទិន្នផលកាន់តែខ្ពស់។ ទន្ទឹមនឹងនោះ យើងក៏ត្រូវដាក់ជី និងមើលថែដីស្រែដោយយកចិត្តទុកដាក់ដែរ។ កុមារក៏មិនខុសពីដើមស្រូវដែរ ដើម្បីឱ្យពួកគេអាចលូតលាស់ ធំធាត់ មានសុខភាពល្អ និងឈ្លាសវៃ យើងត្រូវព្យាយាមផ្តល់ឱ្យពួកគេនូវអាហារូបត្ថម្ភល្អៗ ដើម្បីឱ្យកុមារមានផលិតភាពក្នុងជីវិតរបស់ពួកគេ។

*បន្តការធ្វើបទបង្ហាញ៖* អាហារបន្ថែមត្រូវតែសម្បូរទៅដោយថាមពល ជាតិប្រូតេអ៊ីន និង មីក្រូសារជាតិ។ គួរជ្រើសរើសអាហារដែលងាយស្រួលបរិភោគ និងសមស្របតាមដំណាក់កាលវិវឌ្ឍន៍របស់កុមារ ដូចជា អាហារដែលក្មេងងាយចាប់យកដាក់ក្នុងមាត់។ អាហារចេញពីសាច់សត្វ ដូចជា សាច់ខ្ទរ ឬថ្លើម ត្រី អាហារសមុទ្រ ស៊ុត និងទឹកដោះគោ សុទ្ធតែសម្បូរដោយសារជាតិចិញ្ចឹមជាតិដែក និងជីវជាតិអា។ បើមានគេបន្ថែមជាតិដែកចូលទៅក្នុងអាហារ ដូចជា នំ គ្រាប់ធញ្ញជាតិ និងអាហារផ្សេងៗ  នោះវានឹងជួយឱ្យកុមារអាចបំពេញតម្រូវការជាតិដែកនៅក្នុងរាងកាយរបស់ពួកគេ។

> **កំណត់សម្គាល់**
>
> អាហារបន្ថែមជាអាហារដែលផ្តល់ឱ្យទារកចាប់ពីអាយុ៦ខែ ជាអាហារបង្គ្រប់ទៅលើទឹកដោះម្តាយ ឬទឹកដោះគោជំនួស។ បន្ទាប់ពីអាយុ៦ខែ ទឹកដោះម្តាយ ឬទឹកដោះគោជំនួសតែមួយមុខមិនអាចឆ្លើយតបទៅនឹងតម្រូវការអាហារូបត្ថម្ភបានទេ។ នៅអាយុ៦ខែ រាងកាយកុមារបានវិវឌ្ឍល្មមនឹងអាចបរិភោគអាហារផ្សេងៗ និងបង្កើនសមត្ថភាពប្រើប្រាស់ដៃ អណ្តាត និងមាត់សម្រាប់បរិភោគអាហារ។
>
> កុមារមានការប្រឈមខ្ពស់នឹងកង្វះអាហារូបត្ថម្ភ ប្រសិនបើអាហារបន្ថែមគ្មានសារជាតិចិញ្ចឹមគ្រប់គ្រាន់ ឬមានបរិមាណតិចតួច។ កុមារត្រូវការពេលវេលា និងការជួយជ្រោមជ្រែងខ្លាំង ដើម្បីបំពេញតម្រូវការអាហារូបត្ថម្ភរបស់ពួកគេ ព្រោះក្នុងវ័យនេះ កុមារត្រូវការជំនួយគ្រប់ពេលវេលា សូម្បីតែពេលបរិភោគអាហារ និងទឹក។

បាយ សម្ល និងបបរសមិនគ្រប់គ្រាន់ឱ្យកុមារតូចៗលូតលាស់បានល្អនោះទេ។ កុមារត្រូវការ "បបរខាប់គ្រប់គ្រឿង" (ខាប់ដល់ពេលដួសក៏មិនស្រក់ចេញពីស្លាបព្រាដែរ) ក្នុងបរិមាណត្រឹមត្រូវ។ បបរខាប់គ្រប់គ្រឿងជាបបរដែលមានលាយ៖

### កំណត់សម្គាល់

តម្រូវការជាតិដែកសម្រាប់ទារក និងកុមារតូចៗ៖

- កុមារអាយុ៧–១២ខែ៖ ត្រូវការជាតិដែក១១មីលីក្រាមក្នុងមួយថ្ងៃ ទទួលបានពីការបរិភោគបបរថ្លើមចំនួន៦ស្លាបព្រាបាយ ឬចម្អិនជាមួយបន្លែបៃតងចំណុះ៣/៤ចានចង្កឹះ ឬក៏បបរដែលផ្សំល្ពៅ/ដំឡូងជ្វាកិន៣ចានចង្កឹះ លាយថ្លើមឆ្អិនចំណុះ ៤.៥ស្លាបព្រាបាយ និងបន្លែបៃតងចំណុះកន្លះចានចង្កឹះ។
- កុមារមានអាយុ១-៥ឆ្នាំ៖ ត្រូវការជាតិដែក៩-១០មីលីក្រាមក្នុងមួយថ្ងៃ ដែលទទួលបានពីការបរិភោគថ្លើមមានបរិមាណស្មើនឹងពាក់កណ្តាលចានចង្កឹះ និងបន្លែបៃតងចំណុះមួយចានចង្កឹះ ឬក្រលៀនចម្អិនចំណុះ ២/៤ចានចង្កឹះ ឬបន្លែបៃតងចម្អិនមានចំណុះ១ចានចង្កឹះ ឬតៅហ៊ូ២ចានចង្កឹះ។

ប្រភព៖ តម្រូវការជីវជាតិ និងជាតិខនិជសម្រាប់មនុស្សឆ្នាំ២០០២ របស់អង្គការស្បៀងអាហារ និងកសិកម្ម/អង្គការសុខភាពពិភពលោក។

- ត្រី ស៊ុត ឈាម សាច់ចិញ្ច្រាំ តៅហ៊ូ និងសណ្តែកបាយ
- បន្លែដូចជា ស្លឹកត្រកួន ស្លឹកផ្ទី ល្ពៅ ដំឡូងជ្វា និងបន្លែផ្សេងៗទៀត
- ប្រេងឆា
- អំបិលអ៊ីយ៉ូដ

រូបភាពនេះបង្ហាញពីគ្រឿងផ្សំមួយចំនួនសម្រាប់ចម្អិនបបរខាប់គ្រប់គ្រឿងដែលមានគ្រប់សារជាតិចិញ្ចឹម។ វានឹងជួយឱ្យកុមារដែលបរិភោគបបរនេះមានកម្ពស់ខ្ពស់ រឹងមាំ ឆ្លាត និងរៀនឆាប់ចេះ។



| អាយុ | ភាពញឹកញាប់ | បរិមាណអាហារក្នុង១ពេល | អាហារបន្ថែម |
| --- | --- | --- | --- |
| ៦ ខែ | ២ ដង/ថ្ងៃ | ២-៣ ស្លាបព្រា | ទឹកដោះម្ដាយ យ៉ាងតិច៨ដង |
| ៧-៨ ខែ | ៣ ដង/ថ្ងៃ | ១/២ចាន (២៥០ម.ល) | ទឹកដោះម្ដាយ យ៉ាងតិច៨ដង |
| ៩-១១ ខែ | ៣ ដង/ថ្ងៃ | ជិតពេញមួយចាន | អាហារសម្រន់១ដង/ថ្ងៃ បន្ថែម ទឹកដោះម្ដាយ យ៉ាងតិច៦ដង |
| ១២-២៤ ខែ | ៣ ដង/ថ្ងៃ | ពេញមួយចាន | អាហារសម្រន់ ២ដង/ថ្ងៃ បន្ថែម ទឹកដោះម្ដាយ យ៉ាងតិច៣ដង |

*ប្រភព៖ គោលនយោបាយជាតិស្តីពីការចិញ្ចឹមទារក និងកុមារ*
*មជ្ឈមណ្ឌលជាតិសុខភាពមាតា និងកុមារ ២០០៩*

ចំពោះកុមារដែលមានសុខភាពល្អជាធម្មតា អាហារបន្ថែមដែលត្រូវផ្តល់ឱ្យមានដូចនៅក្នុងតារាងខាងលើ។

ពន្យល់បន្ថែមអំពីព័ត៌មានខាងលើថា៖ ទឹកដោះគឺជាប្រភពដ៏សំខាន់នៃអាហារូបត្ថម្ភរហូតដល់កុមារមានអាយុ២ឆ្នាំ។

*ពន្យល់៖* កុមារដែលបៅដោះម្តាយ ដែលមានពីអាយុ៦ខែទៅ២ឆ្នាំ អាចបំពេញតម្រូវការសារជាតិចិញ្ចឹម និងថាមពលបាន ៥០% ពីទឹកដោះ។ បន្ទាប់ពីអាយុ១២ខែ តម្រូវការអាហារបន្ថែមកើនឡើងកាន់តែច្រើន ហើយកុមារចាប់ផ្តើមបរិភោគអាហារដូចគ្នានឹងអាហារដែលសមាជិកគ្រួសារដទៃបរិភោគដែរ ដូច្នេះធ្វើ ឱ្យតម្រូវការសារជាតិចិញ្ចឹម និងថាមពលរបស់កុមារថយចុះមកត្រឹម៣០%។ ដើម្បីទូទាត់ចំពោះការមិនបានបៅដោះម្តាយ ទារកត្រូវការសារធាតុចិញ្ចឹមពីអាហារក្នុងបរិមាណកាន់តែច្រើន។ ទារកដែលមិនបៅដោះម្តាយ គួរបរិភោគអាហារពេល៤–៥ពេលក្នុងមួយថ្ងៃ និងបន្ថែមអាហារសម្រន់១ឬ២ដងទៀត។ អង្គការសុខភាពពិភពលោកណែនាំឱ្យផ្តល់អាហារឱ្យគ្រប់គ្រាន់តាមតម្រូវការរបស់កុមារ ឬតាមចំណង់បរិភោគរបស់ពួកគេ។

**កំណត់សម្គាល់អំពីទារកដែលរស់នៅជាមួយមេរោគអេដស៍៖**

- កុមារដែលរស់នៅជាមួយមេរោគអេដស៍ត្រូវការថាមពល និងសារជាតិចិញ្ចឹមបន្ថែម ដើម្បីលូតលាស់ និងប្រឆាំងនឹងការឆ្លងរោគផ្សេងៗ ដូច្នេះពួកគេត្រូវការបរិភោគអាហារច្រើនជាងកុមារធម្មតា
- ទារកដែលរស់នៅជាមួយមេរោគអេដស៍តែមិនឈឺគួរទទួលបានអាហារបន្ថែម ១ដង/ថ្ងៃ
- ទារកដែលរស់នៅជាមួយមេរោគអេដស៍ ហើយឈឺ ឬកំពុងស្រកទម្ងន់

គួរទទួលបានអាហារច្រើនជាងកុមារធម្មតា២ដង។

### យុទ្ធសាស្ត្រសម្រាប់កុមារ និងទារក (អាយុពី ៦– ២៤ខែ)៖

- កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ទឹកស្អាត និងអាហារបន្ថែម
- លើទឹកចិត្តម្តាយ/អាណាព្យាបាលក្នុងការថែទាំ និងយកចិត្តទុកដាក់ដល់ទារក
- ផ្តល់អាហារចម្រុះ សម្រាប់ទ្រទ្រង់ការលូតលាស់ឆាប់រហ័សរបស់កុមារក្នុងរយៈពេល ២ឆ្នាំដំបូង
- ត្រូវមានតុល្យភាពអាហារសមរម្យសម្រាប់ការវិវឌ្ឍន៍របស់កុមារ
- ម្តាយឬអណាព្យាបាលគួរលើកទឹកចិត្តឱ្យកុមារបរិភោគអាហារឱ្យបានគ្រប់គ្រាន់ស្របទៅតាមវ័យរបស់ពួកគេ
- ផ្តល់អាហារទៅតាមតម្រូវការ ដោយត្រូវអត់ធ្មត់ និងលើកទឹកចិត្តឱ្យកុមារបរិភោគអាហារ
- កុមារមានអាយុ៦–២៤ខែមានការប្រឈមខ្ពស់នឹងបញ្ហាកង្វះអាហារូបត្ថម្ភ
- បើរកឃើញថាមានការលូតលាស់មិនល្អ ឬអាហារូបត្ថម្ភខ្សត់ខ្សោយត្រូវរកដំណោះស្រាយឱ្យបានឆាប់រហ័ស។

## ជំហានទី២៖ ពិភាក្សាក្រុមអំពី ការបញ្ឈប់វដ្តនៃបញ្ហាកង្វះអាហារូបត្ថម្ភ

រយៈពេល៖ ១៥នាទី

*ការណែនាំអំពីសកម្មភាព៖*

- បែងចែកសិក្ខាកាមជា៦ក្រុម
- បំផុសគំនិតសិក្ខាកាមអំពី វិធីសាស្ត្របញ្ឈប់កង្វះអាហារូបត្ថម្ភនៅក្នុងដំណាក់កាលនៃវដ្តជីវិត
    - » ក្រុមទី១ និងទី២៖ ទារកភាព និងការឈានចូលវ័យកុមារ (អាយុ០-២៤ខែ)
    - » ក្រុមទី៣ និងទី៤៖ កុមារភាព (អាយុ ២-៩ ឆ្នាំ)
    - » ក្រុមទី៥ និងទី៦៖ វ័យជំទង់ (អាយុ ១០-១៩ ឆ្នាំ)
- សុំឱ្យក្រុមនិមួយៗធ្វើបទបង្ហាញពីប្រធានបទរបស់ខ្លួនទៅក្រុមដទៃ
- សម្របសម្រួលការពិភាក្សា និងសង្ខេបខ្លឹមសារ

## កំណត់សម្គាល់៖

ចម្លើយអំពីព័ត៌មានសំខាន់អំពីការបញ្ឈប់វដ្តនៃបញ្ហាកង្វះអាហារូបត្ថម្ភអាចរួមមាន៖

*ទារកភាព និងការឈានចូលវ័យកុមារ(ចាប់ពីកើតរហូតដល់២៤ខែ)*

- បំបៅដោះម្តាយសុទ្ធសម្រាប់ទារកអាយុពី 0-៦ ខែ
- បំបៅទឹកដោះដំបូង (ក្នុងរយៈពេលមួយម៉ោងក្រោយពេលសម្រាល)
- អាហារបន្ថែមសម្រាប់កុមារ ពេលមានអាយុ ៦ខែ
- ផ្តល់អាហារឱ្យបានសមស្រប
- អនាម័យខ្ពស់
- ដោះស្រាយបញ្ហាលូតលាស់មិនល្អ និងកង្វះអាហារូបត្ថម្ភ ឱ្យបានឆាប់រហ័ស
- ឱ្យកុមារបរិភោគ "បបរខាប់គ្រប់គ្រឿង" តាមបរិមាណត្រឹមត្រូវ
- បំបៅដោះកូនឱ្យបានញឹកញាប់ចំពោះកុមារដែលមានជំងឺ
- ចាក់វ៉ាក់សាំងបង្ការ

*កុមារភាព (អាយុចាប់ពី ២-៩ ឆ្នាំ)*

- ផ្តល់អាហារដែលសម្បូរសារជាតិចិញ្ចឹម ដែលបានមកពីក្រុមអាហារទាំងបី
- ចូលរួមតាមដានការលូតលាស់របស់កុមារជាប្រចាំ
- ព្យាបាលរោគសញ្ញា និងការឆ្លងនៃមេរោគអេដស៍ឱ្យបានលឿន
- ការចាក់វ៉ាក់សាំងបង្ការ
- រស់នៅមានអនាម័យល្អ
- ផ្តល់អាហារដែលសម្បូរជីវជាតិអា ជាតិដែក និងជាតិអ៊ីយ៉ូដ

*វ័យជំទង់ (អាយុចាប់ពី ១០-១៩ ឆ្នាំ)*

- ការបង្កើនការបរិភោគអាហារដើម្បីសម្រួលដល់ "សន្ទុះការលូតលាស់"
- បំបាត់កង្វះជាតិដែកតាមរយៈការបរិភោគអាហារដែលសម្បូរជាតិដែក ជាពិសេសសម្រាប់ក្មេងស្រីជំទង់
- បង្ការ និងព្យាបាលការឆ្លងរោគផ្សេងៗ

## ជំហានទី៣៖ ការធ្វើបទបង្ហាញ និងការបំផុសគំនិត

### កុមារអាយុពី ៣-៥ឆ្នាំ (កុមារមត្តេយ្យ)

*បន្តការធ្វើបទបង្ហាញ៖* វ័យមិនទាន់គ្រប់អាយុចូលរៀនជាអំឡុងពេលដែលរាងកាយកុមារមិនមានការលូតលាស់ឆាប់រហ័សទេ ហើយក៏ជាពេលដែលកុមារមិនមានចំណង់បរិភោគខ្លាំងដែរ។ កុមារមួយចំនួនក្នុងក្រុមអាយុនេះ រើសអាហារ និងមិនបរិភោគអាហារណាដែលពួកគេមិនចូលចិត្តឡើយ។ ហេតុដូច្នេះ ត្រូវផ្ដល់អាហារឱ្យបានច្រើនមុខ ទាំងអាហារពេល និងអាហារសម្រន់ ដើម្បីឱ្យកុមារបរិភោគទៅតាមចំណង់ពួកគេពេលគឺគ្មានការបង្ខំ ឬឈ្លោះប្រកែកអ្វីទាំងអស់។ ការបរិភោគអាហារជាប្រចាំពេញមួយថ្ងៃមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យកុមារមានភាពសកម្ម។ ត្រូវឱ្យកុមារបរិភោគអាហារក្នុងបរិមាណល្មម ពី៥–៦ដងក្នុងមួយថ្ងៃ។ កុមារក្នុងវ័យនេះរពឹសខ្លាំងណាស់។ ពួកគេអាចនឹងគិតតែពីលេងនេះលេងនោះ ដោយភ្លេចគិតពីការបរិភោគអាហារក៏មាន។ ជារឿយៗ កុមារតែងចូលចិត្តបរិភោគបាយ ព្រោះបាយមានរសជាតិឆ្ងាញ់សម្រាប់ពួកគេ ហើយពួកគេក៏មិនខ្វល់ពីរសជាតិផ្សេងៗ ឬក៏ប្រភេទអាហារផ្សេងឡើយ។ ការព្យាយាមឱ្យកុមារបរិភោគអាហារឱ្យបានច្រើនប្រភេទអាចជាការលំបាក ហើយវាកាន់តែលំបាកថែមទៀតបើកុមារមិនស្រួលខ្លួន។

កុមារដែលមិនទាន់គ្រប់អាយុចូលរៀនមានក្រពះតូច ដែលធ្វើឱ្យពួកគេមិនអាចបរិភោគអាហារបានច្រើនក្នុងពេលបរិភោគម្ដងៗ។ ពួកគេគួរបរិភោគអាហារដែលសម្បូរសារជាតិចិញ្ចឹម ដើម្បីឆ្លើយតបទៅនឹងតម្រូវការមីក្រូសារជាតិ និងតម្រូវការថាមពលរបស់រាងកាយ។ មីក្រូសារជាតិសំខាន់ៗ សម្រាប់កុមារនៅក្នុងក្រុមអាយុនេះមាន៖

- ជីវជាតិអា៖ សាច់ ថ្លើម ក្រលៀន(សត្វ) ស៊ុតលឿង ត្រីធំតូច បន្លែពណ៌លឿង និងពណ៌ទឹកក្រូច និងផ្លែឈើពណ៌លឿង និងពណ៌ទឹកក្រូច (ឧ. ខ្នុរ ស្វាយទុំ ល្ហុងទុំ)បន្លែស្លឹកពណ៌បៃតងចាស់ (ឧ. ផ្ទី ត្រកួន)។
- ជាតិដែក៖ សាច់ពណ៌ក្រហម សាច់មាន់ ស៊ុត សណ្ដែក តៅហ៊ូ និងបន្លែស្លឹកពណ៌បៃតងចាស់
- អ៊ីយ៉ូដ៖ ប្រើអំបិលអ៊ីយ៉ូដជាគ្រឿងផ្សំក្នុងការចម្អិនម្ហូប
- កាល់ស្យូមសម្រាប់ការលូតលាស់ឆ្អឹង៖ ទឹកដោះគោ តៅហ៊ូ

*សំនួរ៖* ហេតុអ្វីបានជាកុមារមុនអាយុចូលរៀន ជាទូទៅបរិភោគអាហារមិនគ្រប់គ្រាន់?

*ពន្យល់៖* កុមារត្រូវការអាហារឱ្យបានច្រើនមុខ មិនមែនតែអាហារធម្មតាដដែលៗ នៅក្នុងក្រុមណាមួយនោះទេ។ ឧទាហរណ៍ បើកុមារបរិភោគតែបាយមួយមុខក្នុងបរិមាណច្រើន នោះក្រពះពួកគេនឹងគ្មានចន្លោះទំនេរសម្រាប់ដាក់បន្លែ សាច់ ផ្លែឈើ

ទឹកដោះគោ និងតៅហ៊ូ ទេ។ ក្រៅពីអាហារពេល ចូរផ្តល់អាហារសម្រន់ដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ដល់កុមារ ឧទាហរណ៍ ចេកទុំ ស្វាយ ល្ហុង និងទឹកដោះគោ ឬទឹកសណ្តែក។

អាហារូបត្ថម្ភល្អសម្រាប់កុមារក្នុងវ័យមិនទាន់គ្រប់អាយុចូលរៀនមានសារៈសំខាន់ណាស់សម្រាប់អនាគតពួកគេ។ កុមារតូចៗអាយុក្រោមប្រាំឆ្នាំ ដែលរស់នៅជាមួយមេរោគអេដស៍ ងាយរងគ្រោះនឹងកង្វះអាហារូបត្ថម្ភស្រួចស្រាវ។ កុមារដែលរស់នៅជាមួយមេរោគអេដស៍ តែងមានជំងឺកុមារផ្សេងៗ ដូចជា ជំងឺត្រចៀក និងជំងឺស្ងួតញឹកញាប់ជាងកុមារធម្មតា។ រាករូស និងគ្រុនក្តៅ ឧស្សាហ៍កើតមាន និងមានសភាពធ្ងន់ធ្ងរចំពោះកុមារដែលរស់នៅជាមួយមេរោគអេដស៍។ រោគសញ្ញានៃមេរោគអេដស៍ដូចជា រាករូស និងជំងឺឆ្លងផ្សេងៗ នឹងធ្វើឱ្យកុមារខ្វះអាហារូបត្ថម្ភកាន់តែខ្លាំង។ កុមារដែលខ្វះអាហារូបត្ថម្ភយូរអង្វែងនឹងពុំមានការលូតលាស់ល្អដូចការរំពឹងទុកឡើយ។ កុមារនឹងមានកម្ពស់ទាបធៀបនឹងអាយុរបស់គេ (គ្រិន)។

## កុមារអាយុលើសពី៥ឆ្នាំ (កុមារគ្រប់អាយុចូលរៀន)

*ចាប់ផ្តើមការធ្វើបទបង្ហាញដោយនិយាយថា៖* កុមារគ្រប់អាយុចូលរៀនត្រូវការអាហារូបត្ថម្ភល្អដើម្បីឱ្យរាងកាយរបស់ពួកគេលូតលាស់ អាចធ្វើសកម្មភាពផ្សេងៗ រត់លេង និងរៀន ជាដើម។ ពួកគេត្រូវការបរិភោគអាហារពេល ៣ពេល និងអាហារសម្រន់ ២ដងក្នុងមួយថ្ងៃ ដោយមានចម្រុះនូវអាហារទាំងបីក្រុម។

*សំណួរ៖* តើអ្នកនៅចាំក្រុមអាហារទាំង៣ដែលយើងបានរៀនដែរទេ?

*បន្តការធ្វើបទបង្ហាញ៖* កុមារគ្រប់អាយុចូលរៀនប្រឈមនឹងកង្វះអាហារូបត្ថម្ភតិចជាងកុមារតូចៗ ព្រោះរាងកាយរបស់ពួកគេមានការលូតលាស់យឺតជាងនៅតូច។ ការលូតលាស់ឆាប់រហ័សរបស់កុមារមាន៣ដំណាក់កាលផ្សេងៗគ្នាគឺ ក្នុងវ័យទារកភាព វ័យចន្លោះពីអាយុ៦–៨ឆ្នាំ (ឬវ័យលូតលាស់លឿនពាក់កណ្តាល) និងវ័យជំទង់។ កុមារស្ថិតក្នុងវ័យចូលរៀនមានភាពធននឹងការឆ្លងរោគផ្សេងៗ។ ក្រពះរបស់ពួកគេរីកធំជាងមុន ដូច្នេះពួកគេអាចបរិភោគអាហារបានកាន់តែច្រើន។

កុមារគ្រប់អាយុចូលរៀនអាចមានកម្ពស់ទាបធៀបនឹងអាយុ បណ្តាលមកពីកង្វះអាហារូបត្ថម្ភកាលពីពួកគេនៅតូច។ កុមារទទួលរងផលប៉ះពាល់យ៉ាងខ្លាំងបំផុតពីភាពក្រីក្រ អាចត្រូវបានបង្ខំឱ្យបោះបង់ការសិក្សា និងទៅជួយធ្វើការងារដើម្បីបំពេញតម្រូវការជីវភាពប្រចាំថ្ងៃ។ ពេលមានលុយមិនគ្រប់គ្រាន់ កុមារជារឿយៗមិនបានបរិភោគអាហារ។ ប្រការនេះ បង្កើនការប្រឈមនឹងកង្វះអាហារូបត្ថម្ភ និងការចុះខ្សោយនៃសុខភាពរាងកាយ។ ពួកគេត្រូវដើរក្នុងចម្ងាយយ៉ាងឆ្ងាយ ដើម្បីទៅសាលា

ដោយបានបរិភោគអាហារពេលព្រឹកតែបន្តិចបន្តួច ឬក៏មិនបានបរិភោគអ្វីសោះក៏មាន។ ភាពក្រត្រីអាចធ្វើឱ្យកុមាររងគ្រោះកាន់តែខ្លាំង នឹងអាចឈានដល់ភាពមិនប្រក្រតីនៃសុខភាពផ្លូវចិត្ត។

កុមារគ្រប់អាយុចូលរៀនអាចនឹងស្លេកស្លាំង ឬមានខ្វះជីវជាតិអា ដោយសារតែក្នុងរបបអាហាររបស់ពួកគេមិនមានជាតិដែក និងជីវជាតិអាគ្រប់គ្រាន់ ឬអាចបណ្តាលពីការឆ្លងរោគផ្សេងៗ។ ការរក្សាជាតិដែកឱ្យបានគ្រាប់គ្រាន់មានសារៈសំខាន់ណាស់សម្រាប់ការលូតលាស់មុខងារនៃការគិតនិងប្រព័ន្ធភាពស៊ាំរបស់រាងកាយ។ កុមារគ្រប់អាយុចូលរៀនដែលរស់នៅជាមួយមេរោគអេដស៍ត្រូវការអាហារកាន់តែច្រើនដើម្បីបំពេញតម្រូវការអាហារូបត្ថម្ភ ដែលកើនឡើងដោយ សារការឆ្លងមេរោគអេដស៍ ព្រមទាំងដើម្បីទ្រទ្រង់ការលូតលាស់របស់ពួកគេ។

*សំនួរ៖* តើវិធីសាស្ត្រដោះស្រាយអ្វីខ្លះសម្រាប់កុមារ? រំលឹកឡើងវិញនូវចម្លើយរបស់ក្រុមទី៣ និងទី៤ និងត្រូវបំពេញចន្លោះខ្វះខាតបើចាំបាច់។

ចម្លើយរួមមាន៖

- អាហារដែលសម្បូរសារជាតិចិញ្ចឹម បានមកពីក្រុមអាហារទាំងបី
- ថាមពលគ្រប់គ្រាន់ដើម្បីការលូតលាស់
- ចំណង់បរិភោគអាហារ និងការបរិភោគអាហារអាចនឹងប្រែប្រួល។ រាងកាយកុមារអាចស្រូបយកថាមពលបានល្អ នៅពេលដែលពួកគេមានសុខភាពល្អ។
- អនុវត្តអនាម័យល្អ ឧ. លាងសម្អាតដៃនឹងសាប៊ូ ជាមួយទឹកស្អាត
- ផឹកស្អាត គឺមិនត្រូវផឹកភេសជ្ជៈដែលមានជាតិ កាហ្វេអ៊ីន (ឧ. តែ កូកាកូឡា)
- ទទួលទានទឹកផ្លែឈើក្នុងកម្រិតសមរម្យ ចៀសវាងភេសជ្ជៈដែលគ្មានសារធាតុចិញ្ចឹមដូចជា តែ កាហ្វេ សូដា និងភេសជ្ជៈដែលមានជាតិស្ករ ឬភេសជ្ជៈមានពណ៌
- ការព្យាបាលរោគសញ្ញា និងការឆ្លងនៃមេរោគអេដស៍ និងការជ្រៀតចូលនៃមេរោគឱ្យបានទាន់ពេលវេលា (មេរៀនទី៦)
- ចូលរួមតាមដានការលូតលាស់ឱ្យបានជាប្រចាំ និងមានកិច្ចពិភាក្សាដើម្បីធានាឱ្យកុមារលូតលាស់បានល្អ និងអាចដឹងអំពីកង្វះអាហារូបត្ថម្ភដែលពួកគេអាចមាន (ឧ. ស្គមស្គាំងខ្លាំង ឬហើម)
- ព្យាបាលកង្វះអាហារូបត្ថម្ភ
- សារៈសំខាន់នៃការបង្កើតទម្លាប់បរិភោគត្រឹមត្រូវ ឱ្យបានពេញមួយជីវិត។

## វ័យជំទង់ (អាយុពី ១០-១៩ឆ្នាំ)

*ពន្យល់ថា៖* ឥឡូវនេះយើងនឹងសិក្សាពីសារៈសំខាន់នៃអាហារូបត្ថម្ភក្នុងវ័យជំទង់។ ថ្ងៃនេះពួកគេស្ថិតក្នុង វ័យជំទង់ តែថ្ងៃស្អែកពួកគេនឹងក្លាយជាមនុស្សពេញវ័យ។

អង្គការសុខភាពពិភពលោក(WHO) បានកំណត់វ័យជំទង់ស្ថិតក្នុងចន្លោះពីអាយុនៅចន្លោះពី១០ ទៅ ១៩ឆ្នាំ។

## សកម្មភាពបំផុសគំនិត

*សំនួរ៖* ហេតុអ្វីបានជាអាហារូបត្ថម្ភល្អមានសារៈសំខាន់ចំពោះមនុស្សវ័យជំទង់? កត់ត្រា និងពង្រីកគំនិតដែលពួកគាត់ឆ្លើយ នៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។

*បន្តការធ្វើបទបង្ហាញ៖* វ័យជំទង់គឺជាផ្នែកដ៏សំខាន់មួយនៃការអភិវឌ្ឍន៍របស់រូបរាងកាយនៅក្នុងវដ្តជីវិត។ ហើយវាក៏ជាពេលដែលមានការផ្លាស់ប្តូរទាំងរូបរាងកាយ និងផ្លូវចិត្តដែរ។ ល្បឿននៃការលូតលាស់របស់រូបរាងកាយមានភាពឆាប់រហ័សតែនៅក្នុងឆ្នាំដំបូងនៃជីវិតប៉ុណ្ណោះ។ ហេតុដូច្នេះ វ័យជំទង់ផ្តល់នូវឱកាសម្តងទៀតក្នុងការលូតលាស់ដើម្បីបំពេញតុល្យភាពរាងកាយដែលខ្វះខាតក្នុងវ័យទារកភាព។ ការទទួលបានអាហារូបត្ថម្ភល្អមុនពេលពេញវ័យ (ប្រហែល១៨–២៤ខែ បន្ទាប់ពីរដូវដំបូង សម្រាប់ក្មេងស្រី) គឺជាឱកាសក្នុងការបំពេញតម្រូវការអាហារូបត្ថម្ភដែលខ្វះខាតក្នុងដំណាក់កាលកុមារភាព។

កាលណាក្មេងជំទង់មានការលូតលាស់កម្ពស់ល្អ វានឹងផ្តល់ប្រយោជន៍យ៉ាងច្រើននៅពេលពួកគេក្លាយទៅជាមនុស្សពេញវ័យ ដូចជាសមត្ថភាពបំពេញការងារខ្ពស់ ងាយស្រួលក្នុងការផ្តល់កំណើតកូន និងកាត់បន្ថយគ្រោះថ្នាក់ ចំពោះមាតានៅពេលសម្រាល និងជួយកាត់បន្ថយលទ្ធភាពក្នុងការបង្កើតកូនមិនគ្រប់ទម្ងន់។

ក្មេងប្រុស និងក្មេងស្រីមានដំណើរនៃការលូតលាស់ពេញវ័យខុសគ្នា។ ក្មេងស្រីចាប់ផ្តើមលូតលាស់លឿន ជាមធ្យមនៅអាយុ១០ឆ្នាំ និងលូតលាស់លឿនបំផុតនៅអាយុ១២ឆ្នាំ។ ចំណែក ក្មេងប្រុសចាប់ផ្តើមលូតលាស់លឿន ជាមធ្យមនៅអាយុ១២ឆ្នាំ និងលូតលឿនបំផុតនៅអាយុ១៥ឆ្នាំ។ ក្មេងស្រីលូតកម្ពស់ដល់ចំណុចអតិបរិមានៅអាយុ១៦ឆ្នាំ ចំណែកក្មេងប្រុសកម្ពស់ដល់ចំណុចអតិបរិមានៅអាយុ១៨ឆ្នាំ។

វ័យជំទង់ជាវ័យដែលរាងកាយត្រូវការអាហារូបត្ថម្ភយ៉ាងចាំបាច់បំផុតពីព្រោះ ការលូតលាស់លឿន និងការវិវឌ្ឍន៍នៃរូបរាងកាយបង្កឱ្យមានតម្រូវការសារជាតិចិញ្ចឹមកាន់តែច្រើន។ រាងកាយត្រូវការសារជាតិចិញ្ចឹម (ប្រូតេអ៊ីន កាល់ស្យូម ជាតិដែក) និងថាមពលបន្ថែម ដោយសារតែការលូតលាស់របស់រាងកាយ ការប្រែក្លាយជាមនុស្សពេញវ័យ និងការប្រែប្រួលនៃសមាសភាពរាងកាយមានការកើនឡើង។ ការស្រូបយកអាហារ និងសារជាតិចិញ្ចឹមរបស់រាងកាយក្មេងវ័យជំទង់រងឥទ្ធិពលពីកត្តាជាច្រើនដូចជា សេដ្ឋកិច្ច-សង្គម វប្បធម៌ និងបំលាស់ប្តូរនៃការរស់នៅ។ តម្រូវការសារជាតិចិញ្ចឹមកើនឡើងកាន់តែខ្លាំងនៅពេលដែលរាងកាយចាប់ផ្តើមលូតលាស់ខ្លាំង ឬនៅពេលដែលស្ត្រីមានផ្ទៃពោះនៅវ័យក្មេង។

ក្មេងជំទង់តែងចង់បរិភោគអាហារច្រើនមុខខុសៗគ្នា ដូចដែលពួកគេធ្លាប់បានបរិភោគកាលពីនៅក្មេង។ ពួកគេនឹងមានទម្លាប់បរិភោគអាហារពេល និងអាហារសម្រន់នៅខាងក្រៅ ដោយគ្មានការគ្រប់គ្រង។ ជារឿយៗ ការបរិភោគអាហាររបស់ពួកគេមិនបានកំណត់បរិមាណត្រឹមត្រូវឡើយ។ ភាពមមាញឹកនៅសាលារៀន និងសកម្មភាពប្រចាំថ្ងៃអាធ្វើឱ្យពួកគេមិនអាចនៅបរិភោគតែអាហារមិនបានគ្រប់គ្រាន់ ឬពេលខ្លះអាចនឹងមិនបរិភោគអាហារពេល ឬអាហារសម្រន់ផងក៏មាន។ ការបរិភោគអាហារ តិចៗ តែញឹកញាប់ (ឧទាហរណ៍៦ដងក្នុងមួយថ្ងៃ) គឺជាប្រការល្អបំផុតដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលរបស់ក្មេងនៅក្នុងក្រុមអាយុនេះ។ នៅពេលដែលមនុស្សជំទង់មិនបានបរិភោគ អាហារពួកគេនឹងបរិភោគអាហារដែលគ្មានប្រយោជន៍ដូចជា ភេសជ្ជៈ បង្អែម និងជំឡូងបំពង ជាដើម ដែលក្នុងអាហារទាំងនោះមានសារធាតុចិញ្ចឹមតិចតួចបំផុត។

## *គោលដៅរបស់ក្មេងជំទង់៖*

- បំពេញតម្រូវការសារជាតិចិញ្ចឹមខ្ពស់ តាមរយៈការបរិភោគអាហារផ្សេងៗឱ្យបានគ្រប់គ្រាន់
- លូតលាស់ពេញលេញ និងលូតកម្ពស់ដល់ចំណុចអតិបរមាមាននៅពេលពេញវ័យ
- បានទទួលការព្យាបាលរោគសញ្ញានៃមេរោគអេដស៍ទាន់ពេលវេលាដើម្បីចៀសវាងការចំណាយថាមពលរាងកាយច្រើន និងកត្តាដែលអាចបន្ថយដល់ការស្រូបយកសារជាតិចិញ្ចឹម ដូចជាការមិនឃ្លានបាយ និងរាករ៉ាំរ៉ៃ។
- មានសុខភាពល្អគ្រប់គ្រាន់ដើម្បីចូលសាលារៀន និងមានការវិវឌ្ឍន៍ការគិតបានប្រសើរបំផុត
- ទទួលបានជាតិកាល់ស្យូម និងជីវជាតិដេ បានច្រើនបំផុតដើម្បីឆ្អឹងលូតលាស់ល្អ និងរឹងមាំ
- មានផ្ទៃពោះក្រោយពេលការលូតលាស់បានចប់សព្វគ្រប់។ ការមានផ្ទៃពោះក្នុងវ័យជំទង់មិនត្រឹមតែធ្វើឱ្យមានគ្រោះថ្នាក់ខ្ពស់ដល់ម្ដាយ និងទារកទេ វាថែមទាំងបង្អាក់ដល់ការវិវឌ្ឍន៍ផ្លូវកាយ ផ្លូវចិត្ត និងសង្គមរបស់ម្ដាយផងដែរ។ ក្នុងករណីមានផ្ទៃពោះនៅវ័យជំទង់ ទាំងម្ដាយ និងទាំងទារកក្នុងផ្ទៃ ប្រជែងគ្នាក្នុងការស្រូបយកថាមពល និងសារជាតិចិញ្ចឹមដើម្បីបំពេញតម្រូវការរៀងៗខ្លួន។

## *បញ្ហាទូទៅរបស់ក្មេងជំទង់៖*

- រោគសញ្ញាមេរោគអេដស៍អាចធ្វើឱ្យការបរិភោគ និងការបឺតស្រូបអាហារធ្លាក់ចុះ(ដូចគ្នានឹងមនុស្សពេញវ័យដែរ)
- ការស្រកទម្ងន់អាចបណ្ដាលមកពីការស្រូបយក ឬការបរិភោគអាហារមិនគ្រប់គ្រាន់ រួមជាមួយតម្រូវការថាមពលខ្ពស់
- សមត្ថភាពការងារ និងបញ្ញាអាចធ្លាក់ចុះ ដោយសារកង្វះអាហារូបត្ថម្ភរយៈពេលយូរ និងការលូតលាស់មិនល្អ

- ស្លេកស្លាំងដោយសារកង្វះជាតិដែក ដែលអាចបណ្តាលមកពីការស្រូបយកជាតិដែកពីរបបអាហារមិនគ្រប់គ្រាន់ ក្នុងខណៈពេលមានតម្រូវការជាតិដែកខ្ពស់ ដោយសារការលូតលាស់លឿនក្នុងវ័យជំទង់ និងការមករដូវរបស់ក្មេងស្រី
- ការលូតលាស់យឺត និងភាពយឺតយ៉ាវក្នុងការពេញវ័យ អាចបណ្តាលមកពីកង្វះអាហារូបត្ថម្ភរយៈពេលយូរ។
- ការមានផ្ទៃពោះក្នុងវ័យជំទង់ (ដូចដែលបានពិភាក្សាខាងលើ)
- សុខភាពផ្លូវចិត្ត និងសុខភាពសង្គមអាចចុះខ្សោយ
- ការប្រើប្រាស់ថ្នាំញៀន ថ្នាំជក់ និងជាតិស្រាអាចធ្វើឱ្យរាងកាយស្រូបយកអាហារមិនល្អ គ្មានសុវត្ថិភាពចំណីអាហារ និងមានបញ្ហាសុខភាពផ្លូវចិត្ត។

*វិធីសាស្ត្រដោះស្រាយសម្រាប់ក្មេងជំទង់៖*

- ដើម្បីឱ្យក្មេងជំទង់អាចឆ្លើយតបនឹងតម្រូវការអាហារូបត្ថម្ភរបស់ខ្លួនបាន ពួកគេត្រូវដឹងថាពួកគេត្រូវបរិភោគអាហារអ្វី និងក្នុងបរិមាណប៉ុន្មាន។ ការអប់រំ និងចំណេះដឹងអំពីអាហារ និងអាហារូបត្ថម្ភនឹងជួយឱ្យក្មេងវ័យជំទង់អាចឆ្លើយតបបានទៅនឹងតម្រូវការអាហារូបត្ថម្ភ និងលើកកម្ពស់សុខភាពរបស់ពួកគេ។
- ការបរិភោគអាហារដែលសម្បូរជាតិស័ង្កសី កាល់ស្យូម ជាតិដែក និងជីវជាតិអាដែលបានមកពីអាហារចម្រុះ និងអាហាបំប៉ន ឬគ្រាប់វីតាមីន នឹងជំរុញឱ្យមានអាហារូបត្ថម្ភគ្រប់គ្រាន់។
- រោគសញ្ញា និងស្ថានភាពជំងឺធ្វើឱ្យមានការស្រូបចូលអាហារមិនបានល្អ ដូច្នេះគួរតែព្យាបាលឱ្យឆាប់រហ័សដើម្បីកាត់បន្ថយផលប៉ះពាល់ក្នុងការស្រូបយកអាហារមិនបានល្អរយៈពេលយូរ (មើលមេរៀនទី ៦)។
- ទទួលបានការអប់រំ  និងថែទាំសុខភាព រួមមានការពន្យាកំណើត ឬការពន្យាការមានផ្ទៃពោះរហូតដល់ក្មេងស្រីជំទង់ជាម្តាយលូតលាស់បានពេញលេញ និងដល់កម្ពស់អតិបរមាសិន។
- ទៅរក ឬស្វែងរកនូវការគាំទ្រពីសង្គម និងផ្នែកសុខភាពផ្លូវចិត្ត។

*មនុស្សពេញវ័យ (អាយុ១៩ឆ្នាំឡើងទៅ)*

*ពន្យល់សិក្ខាកាមថា៖* នៅពេលយើងឈានដល់ដំណាក់កាលពេញវ័យ ភាគច្រើនការលូតលាស់ និងការអភិវឌ្ឍន៍របស់យើងមានលក្ខណៈប្រសើរ និងត្រូវបញ្ចប់។ នៅក្នុងដំណាក់កាលនេះ អាហារូបត្ថម្ភមានមុខងារថែរក្សាសុខភាពឱ្យបានល្អ និងឱ្យមានសកម្មភាពជីវិតរស់រវើក ដូច្នេះមនុស្សពេញវ័យនឹងអាចចៀសផុតស្ទើរទាំងស្រុងពីគ្រោះថ្នាក់ដែលបណ្តាលមកពីជំងឺតាមវ័យ។ មិនថាយើងមានអាយុប៉ុន្មានទេ រាងកាយយើងនៅត្រូវការរបបអាហារដែលមានជីវជាតិ ដើម្បីបំពេញមុខងារសរីរាង្គឱ្យបានល្អ។ មនុស្សពេញវ័យត្រូវការរបបអាហារដែលមានសារជាតិចិញ្ចឹម និងបរិមាណដែលមានតុល្យភាព ដែលទទួលបានមកពីក្រុមអាហារទាំងបី។

ការរៀបចំអាហារ និងទុកដាក់ឱ្យមានអនាម័យល្អពិតជាមានសារៈសំខាន់ណាស់ ដើម្បីបង្ការជំងឺ។ មនុស្សប្រុសត្រូវការកាឡូរីច្រើនជាងមនុស្សស្រី ប៉ុន្តែមនុស្សស្រីត្រូវការជាតិដែកច្រើនជាងមនុស្សប្រុស។

ចាំបាច់ត្រូវធ្វើលំហាត់ប្រាណ និងចលនារាងកាយឱ្យបានច្រើនជាង៣០នាទីក្នុងមួយថ្ងៃ ដើម្បីថែរក្សាសុខភាពឱ្យបានល្អ។ ទម្ងន់ដែលមានសុខភាពល្អធម្មតាអាចបង្ហាញតាមរយៈការដែលមនុស្សម្នាក់មិនស្គមពេក ឬមិនធាត់ពេក។ នៅពេលដែលមនុស្សមានទម្ងន់ដែលមានសុខភាពល្អធម្មតា ពួកគេប្រឈមគ្រោះថ្នាក់ទាបចំពោះការវិវត្តន៍នៃជំងឺ ឬមេរោគផ្សេងៗ។ ពួកគេនឹងមានភាពរស់រវើក អារម្មណ៍ល្អ និងមានថាមពលគ្រប់គ្រាន់សម្រាប់សកម្មភាពប្រចាំថ្ងៃ។

## ជំហានទី៤៖ សំណួរសាកល្បង និងល្បែង (ល្បែងសន្ទឹង)

គោលបំណងនៃល្បែងនេះ គឺដើម្បីផ្តល់ឱកាសឱ្យសិក្ខាកាមបង្ហាញពីចំណេះដឹងរបស់ពួកគេ និងសន្ទឹងខ្លួនរបស់គេ និងកាត់បន្ថយអារម្មណ៍អស់កម្លាំង។

សុំឱ្យសិក្ខាកាមឈរមួយជួរ ពីទាបទៅខ្ពស់។ ឱ្យក្រដាសស្អិតទៅសិក្ខាកាមម្នាក់មួយសន្លឹក និងសរសេរលេខលើក្រដាសស្អិតនីមួយៗ (ពីលេខ១ដល់លេខខ្ពស់បំផុត)។ ចាប់ផ្តើមជាមួយអ្នកដែលទាបជាងគេ សួរគាត់មួយសំណួរ (ដែលមានក្នុងជំហានទី២ ល្បែងចោទសួរ នៃគោលបំណងទី៣ )។ នៅពេលគាត់ឆ្លើយសំណួរបានត្រឹមត្រូវ ប្រាប់ឱ្យគាត់សន្ទឹងដៃឡើងឱ្យខ្ពស់ រួចបិតក្រដាសស្អិតនោះទៅលើជញ្ជាំងឱ្យខ្ពស់បំផុតតាមដែលគាត់អាចធ្វើបាន។ គាត់អាចលោតបានបើគាត់ចង់។

បើសិក្ខាកាមមានចំនួនច្រើនជាងសំណួរ អ្នកសម្របសម្រួលអាចប្រើសំណួរដដែលមួយចំនួន ឬបង្កើតសំណួរថ្មីដែលទាក់ទងនឹងមេរៀន។ សិក្ខាកាមនីមួយៗត្រូវឆ្លើយសំណួរឱ្យបានត្រឹមត្រូវ មុនពេលពួកគេអាចបិទលេខរបស់ពួកគេនៅលើជញ្ជាំង។ ប្រសិនបើពួកគេមិនដឹងចម្លើយត្រឹម ពួកគេអាចទទួលជំនួយពីអ្នកស្ម័គ្រចិត្តផ្សេងបាន ប៉ុន្តែអ្នកដែលឆ្លើយមិនត្រូវ មិនអាចចូលរួមប្រកួតក្នុងការសន្ទឹងបិតក្រដាសទេ។ សិក្ខាកាមដែលអាចបិតលេខបានខ្ពស់ជាងគេនៅលើជញ្ជាំងគឺជាអ្នកឈ្នះ។ អបអរសាទរពួកគេ។

### សង្ខេបខ្លឹមសារមេរៀន

សុំឱ្យសិក្ខាកាមមើលឯកសារមេរៀនទីពីរ (សៀវភៅសម្រាប់សិក្ខាកាម) ហើយប្រាប់ពួកគេថា រាល់ព័ត៌មានទាំងអស់ដែលបានពិភាក្សាកន្លងមកក្នុងមេរៀនទីពីរគឺមាននៅក្នុងឯកសារមេរៀននេះ។